# វប្បធម៌_អរិយធម៌ខ្មែរ



ស្ដីអំពី

ក. របាប់ថ្ងៃ ខែ ឆ្នាំ

ខ. របាប់ទសវត្ស

សតវត្ស សហស្សវត្ស

គ. របាប់រកអាយុ និង

រកឆ្នាំកំណើត

ឃ. ពិធីរកឈ្មោះសករាជ

លី សុវីរ

5

បោះពុម្ពលើកទី២

ព.ស ២៥៥១ គ.ស ២០០៧

PB.2007..........
306.9596
ស៊ុវ
ភ្នំ 1

# វប្បធម៌_អរិយធម៌ខ្មែរ

## ស្ដីអំពី

ក. របាប់ថ្ងៃ ខែ ឆ្នាំ

ខ. របាប់ទសវត្ស, សតវត្ស, សហស្សវត្ស

គ. របាប់រកអាយុ និង រកឆ្នាំកំណើត

ឃ. ពិធីរកឈ្មោះសករាជ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
015909

អ្នកនិពន្ធ

អតីតសាស្ត្រាចារ្យមធ្យមសិក្សា **លី ស៊ុវីរ**

រក្សាសិទ្ធិ

បោះពុម្ពលើកទី២

ព.ស ២៥៥១ គ.ស ២០០៧

# អារម្ភកថា

◇◇◇◇◇

ដោយយល់ឃើញថា **វប្បធម៌ អរិយធម៌**របស់ខ្មែរ ខ្មែរលែងចេះ លែងស្គាល់ លែងបានគិតថា អ្វីជាវប្បធម៌ អរិយធម៌ របស់ខ្លួន សូម្បីរាប់ថ្ងៃ ខែ ឆ្នាំរបស់ខ្មែរ ខ្មែរខ្លះមិនចេះរាប់ថ្ងៃ ខែ ឆ្នាំ របស់ខ្មែរផង បែរជាចេះរាប់ថ្ងៃ ខែ ឆ្នាំរបស់សកលទៅ វិញពីព្រោះអ្វី ?

ព្រោះប្រទេសខ្មែរ មានសង្គ្រាមរ៉ាំរ៉ៃ អស់ជាង ពាទស្សវត្ស ធ្វើអោយខ្មែរក្រលំបាក ខំរកស៊ីចិញ្ចឹមជីវិតខ្លួន ខ្មែរម្នាក់ៗ មិនបាន គិតពីវប្បធម៌ អរិយធម៌របស់ខ្លួនឡើយ ។

លុះមានចិត្តយល់ឃើញបែបនេះទើបធ្វើអោយខ្ញុំខំសរសេរ សៀវភៅនេះរហូតដល់បានសំរេចដូចបំនង ។ កាលបើធ្វើបាន សំរេចដូចបំនងហើយ ទើបខ្ញុំយកទៅជូន :

១. ឯកឧត្តម ស្វ មុយឃៀង

២. ឯកឧត្តម លី សុម្មុនី

៣.ឯកឧត្តម ពេជ្រ ឆុំក្រាទិល

៤. លោក មៀច ប៉ុណ្ណ

៥. លោក គួច ចុំងហាក់

លោកទាំង ៥ មានយោបល់ :

១.ឯកឧត្តម សូ មុយឃៀង បានជួយកែសំរួលពាក្យពេចន៍ខ្លះ និងបានអោយយោបល់ :

សៀវភៅនេះ មានប្រយោជន៍ច្រើនណាស់ សំរាប់កូនខ្មែរជំនាន់ក្រោយ ព្រោះបានបង្រៀនយើង អោយចេះរកអាយុ រកឆ្នាំកំនើត តាមក្បួនបុរាណខ្មែរ និងចេះប្រើស័ក ទសវក្ស សតវក្ស សហស្សវក្ស បានត្រឹមត្រូវល្អ ។

ភ្នំពេញ, ថ្ងៃទី ៣ ឧសភា ឆ្នាំ ២០០២

សូ មុយឃៀង

២.ឯកឧត្តម លី សុមុនី បានជួយកែសំរួលនិងបានអោយយោបល់ :

សៀវភៅនេះ ជាវិភាគទានដ៏សំខាន់ សំរាប់ជំនាន់ក្រោយ អោយយល់ពីរបៀបរាប់ ថ្ងៃ ខែ ឆ្នាំរបស់ខ្មែរយើង ពីសម័យបុរាណ និងដើម្បីពង្រស់ឡើងវិញ ពីវប្បធម៌ អរិយធម៌ ដែលបច្ចុប្បន្នស្ទើរតែរលាយបាត់បង់អស់ទៅហើយ ។

ភ្នំពេញ.ថ្ងៃទី ១ ឧសភា ឆ្នាំ ២០០២

លី សុមុនី

៣-ឯកឧត្តមពេជ្រ ទុំត្រាវិល លោកមិនមានយោបល់ចុះក្នុងអត្ថបទទេ លោកគ្រាន់តែបានធ្វើសំនួមពរ តាមអ្នកយកអត្ថបទ មក ប្រគល់អោយថា ពាក្យរចាប់ សូមកែទៅជា ការរាប់ រី ក្បួនរាប់ ប្រសិនបើអាចកែទៅបាន ។

៤-លោក មៀច ប៉ុណ្ណ មានយោបល់ :

សៀវភៅនេះ មានសារៈសំខាន់ ផ្នែកជំនួយស្មារតីក្នុងការ រាប់អាយុ និងសករាជ ទសវត្ស សតវត្ស សហស្សវត្ស ។ ប្រសិន បើលះបង់លែងបង្រៀនកូន ចៅ យុវជនជំនាន់ក្រោយអោយចេះ ដឹងអំពី ប្រពៃណី ទំនៀមទំលាប់ រាប់ថ្ងៃ ខែ ឆ្នាំ តាមចន្ទគតិ បែបខ្មែរនិយមទេ យើងនិងបាត់បង់អស់វប្បធម៌យើងនៅពេលខ្ញី ខាងមុខជាមិនខាន។

ភ្នំពេញ. ថ្ងៃ ២។ ៦ / ៣ ព.ស.២៥៤៦ / គ.ស.២០០២

មៀច ប៉ុណ្ណ

៥. លោក គួច ថុងហាក់ មានយោបល់ ៖

ចំពោះសៀវភៅ វប្បធម៌ និង អរិយធម៌ខ្មែរនេះមាន ប្រយោជន៍សំខាន់ណាស់ ចំពោះកុលបុត្រ-កុលធីតាខ្មែរ ។

២០-៥-២០០២

**គួច ថុងហាក់**

ក្នុងនាមអ្នកនិពន្ធ សូមលើកសៀវភៅទាំងមូល ជូនបណ្ដាជនទាំងអស់ មេត្តាជួយរិះគន់ស្ថាបនា ដើម្បីធ្វើអោយសៀវភៅនេះ មានជីវិតរស់នៅបានយូរ នៅក្នុងសង្គមខ្មែរ ។

៤

ភ្នំពេញ, ថ្ងៃ ៤ ។ ៧ ឆ្នាំ មមី ព.ស.២៥៤៦

ត្រូវនឹងថ្ងៃ ១៥ ឧសភា ២០០២

**លី សុធីរ**

*អតីតសាស្ត្រាចារ្យមធ្យមសិក្សា*

*វក្សាសិទ្ធិ*

# ប្រវត្តិរូបសង្ខេប



## លី សុវីរ

**លី សុវីរ** កើតនៅថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំរោង ព.ស.២៤៧២ ត្រូវនឹងថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩២៨ នៅភូមិឬស្សីថ្មង់ ឃុំបឹងព្រះ ស្រុកបាភ្នំ ខែត្រព្រៃវែង ឪពុកព្រះនាម **លី អែម** ម្ដាយព្រះនាម **ខិន ខ៊ាន់** ។

ពីអាយុ ១ឆ្នាំ រហូតដល់អាយុ ២០ឆ្នាំ នៅជាមួយឪពុកម្ដាយខំរកស៊ីបំរើឪពុកម្ដាយ គ្មានបានរៀនសូត្រអ្វីទាំងអស់។ លុះដល់អាយុ ២១ឆ្នាំ ឪពុកម្ដាយបានអនុញ្ញាតអោយបួសរៀននៅវត្តសិរីមង្គល ហៅព្រៃរវាយ ដែលជាវត្តកេរដំនែលពីឪពុក ស្ថិតនៅក្នុងឃុំទឹកថ្លា ស្រុកបាភ្នំ ខែត្រព្រៃវែង បួសនៅក្នុងសំនាក់ព្រះតេជព្រះគុណ គង់ យី ជាព្រះឧបជ្ឈាយ៍. ព្រះតេជព្រះគុណ លី អ៊ុម ជាឧបសម្បទាចារ្យ ។

លុះដល់អាយុ ២២ឆ្នាំ បានចេញទៅរៀនភាសាបាលី នៅវត្តព្រៃទំពូង, វត្តព្រែកចង្ក្រានលើ, វត្តសារាវ័ន, វត្តឧណ្ណាលោម ។ នៅក្នុងគ.ស.១៩៥៦ បានប្រលងជាប់ចូលរៀន នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។ លុះដល់គ.ស.១៩៦៦ បានប្រលងបញ្ចប់បរិញ្ញាប័ត្រទស្សនវិជ្ជាសាសនា នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។

ពេលលាចាកសិក្ខាបទ នៅឆ្នាំ ១៩៦៦ បានធ្វើជាសាស្ត្រាចារ្យនៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ១ឆ្នាំ បានធ្វើការនៅសូណាព្រីម ២ឆ្នាំ ។

នៅឆ្នាំ ១៩៦៧ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាង ឡាយ ប៊ុនណា នៅភូមិព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានកូនស្រី ៤នាក់ និងកូនប្រុស ៣នាក់ ។ បច្ចុប្បន្នស្លាប់អស់ ២នាក់ នៅសល់កូនស្រី ៣នាក់ និងកូនប្រុស ២នាក់ ។

នៅឆ្នាំ ១៩៦៩ បានធ្វើជាសាស្ត្រាចារ្យ នៅវិទ្យាល័យសិរីមង្គល (រកាកោង) ។ នៅឆ្នាំ ១៩៧២ ធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យខ្មែរអង់គ្លេស (បឹងត្របែក) ។ នៅឆ្នាំ ១៩៧៥ ទៅនៅស្រុកកំណើត ។ នៅឆ្នាំ ១៩៧៩ ធ្វើគ្រូនៅសាលាបឋមសិក្សាវត្តបឹងព្រះ ។ នៅឆ្នាំ ១៩៨០ ធ្វើជាអ្នកនិពន្ធសៀវភៅសិក្សានៅក្រសួងអប់រំ ។ នៅឆ្នាំ ១៩៩៧ ខែតុលា ចូលនិវត្តន៍ ។

**លី សុធីរ**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

រក្សាសិទ្ធ

# វប្បធម៌_អរិយធម៌ខ្មែរ

## ក_ស្តីអំពី

## របាប់ថ្ងៃ ខែ ឆ្នាំ

ꩳꩳꩳꩳꩳꩳꩳ

នៅក្នុងលោក មានមនុស្សរស់នៅច្រើនជនជាតិណាស់ តែជនជាតិនីមួយ ៗ មានភាសា ប្រពៃណីរបស់ខ្លួន ធ្វើអោយជនជាតិនីមួយៗនោះ មានលក្ខណៈដាច់ដោយឡែកពីគ្នា ។ គេតែងខំថែរក្សា ភាសានិងប្រពៃណីរបស់ខ្លួនអោយបានគង់វង្ស ពីព្រោះគេខ្លាចបាត់ជាតិរបស់ខ្លួន ( ភាសារលត់ ជាតិរលាយ ខ្លះគេថាវប្បធម៌រលត់ ជាតិរលាយ. ខ្លះគេថាប្រពៃណីរលត់ជាតិរលាយ)។

របាប់ ថ្ងៃ ខែ ឆ្នាំ របស់ជនជាតិទាំងអស់ ដែលរស់នៅក្នុងលោក គេអាចចែកបានជាពីរប្រភេទ គឺរបាប់តាមចន្ទគតិ និងរបាប់តាមសុរិយគតិ។

របាប់តាមចន្ទគតិ មានប្រទេសខ្មែរ.ចិន.យួន.…។ ឯប្រទេសដែលរាប់តាមចន្ទគតិនេះទៀត មិនមានលក្ខណៈដូចគ្នាទេ គឺគេរាប់តាមប្រពៃណីរៀងៗ ខ្លួន ។

ឱ-ជនជាតិខ្មែរ រាប់ថ្ងៃ ១កើត ខែមិគសិរ រៀងរាល់ឆ្នាំជាថ្ងៃទី១ ។ ឯជនជាតិ ចិន,យួន,... វិញ គេរាប់ថ្ងៃ១កើត ខែមាឃខ្មែរជារៀងរាល់ឆ្នាំ ធ្វើជាថ្ងៃទី ១ របស់គេ ។

ការប្រើប្រាស់ ថ្ងៃ ខែ ឆ្នាំ តាមប្រពៃណីខ្មែរ ពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ឃើញនៅសល់ការប្រើមាន ៣ បែប :

១-មុនសម័យបារាំង លោកប្រើតាមចន្ទគតិសុទ្ធមិនមានប្រើសុរិយគតិឡើយ ឱ-នៅក្នុងសៀវភៅវចនានុក្រមខ្មែរ របស់សម្តេចសង្ឃរាជ ជ.ណ.ទំព័រ ១៩៩ ពាក្យចុល្លសករាជ ព្រះអង្គបានបញ្ជាក់ថា កាលដែលតាំងចុល្លសករាជ នៅថ្ងៃចន្ទ ១២កើតខែចេត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ១១៨៣,... ។

២- សម័យបារាំង លោកប្រើចន្ទគតិផង សុរិយគតិផង ( ប្រហែលជាសម័យបារាំងសែសត្រួតត្រាខ្មែរទេដឹង ? ) លោកប្រើមាន ២ បែប :

ក-ថ្ងៃពុធ ៣ រោច ខែពិសាខ ឆ្នាំថោះ ត្រីស័ក ព.ស. ២៤៩៣ ត្រូវនឹងថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៥១ (អារម្ភកថា

សៀវភៅ បទានុក្រមបាលី អភិធានប្បទីបិកា របស់ព្រះឧបាលិ វង្ស មឹង សែស ) ។

ខ.នៅក្នុងឯកសារនានា គេប្រើនសរសេរបែបនេះវិញៈ

ថ្ងៃ ៤ ។ ៦ ឆ្នាំថោះ ត្រីស័ក ព.ស.២៤៩៣ ត្រូវនឹងថ្ងៃទី ២៣ ខែ
៣
ឧសភា ឆ្នាំ ១៩៥១ ។ មើលវចនានុក្រម សម្តេចព្រះសង្ឃរាជ ជ.ណ. ឧ_ពាក្យរោច ទំព័រ ១០៧០,...។

នៅតាមសំបុត្រចុតម៉ាយនានា និងនៅតាមឯកសារនានា ជាច្រើន គេសរសេរតាមឧ.ខ នេះស្ទើរតែទាំងអស់ ។

៣.ក្រោយសម័យបារាំង លោកប្រើតែសុរិយគតិសុទ្ធ មិនមានប្រើចន្ទគតិឡើយ ធ្វើរោយក្ទួយៗ លែងស្គាល់ លែងបេះ របៀបរាប់ចន្ទគតិ ដែលជាវប្បធម៌ អរិយធម៌ខ្មែរឡើយ ។ គេចុះ នៅក្នុងអត្ថបទនានា រឺ លិខិតនានាថា ធ្វើនៅភ្នំពេញ,ថ្ងៃទី ២០ ខែកុម្ភៈ គ.ស.២០០២ ។

## I- របាប់តាមចន្ទគតិ

របាប់តាមចន្ទគតិ ជារបាប់តាមវប្បធម៌ អរិយធម៌ខ្មែរតាំងពីបុរាណកាលមក ។

ក_របាប់តាមចន្ទគតិ

ក.១.របាប់ថ្ងៃ

ក្នុង ១ សប្តាហ៍មាន ៧ ថ្ងៃ

អាទិត្យ.ចន្ទ.អង្គារ.ពុធ.ព្រហស្បតិ៍.សុក្រ.សៅរ៍ ។

ក.២.របាប់ខែ ១២

របាប់ខែ តាមចន្ទគតិ មាន

| | | |
|---|---|---|
| . មិគសិរ | ខែទី ១ | ក្តាន់ មាន២៩ ថ្ងៃ |
| . បុស្ស | ខែទី ២ | ក្តាម មាន៣០ ថ្ងៃ |
| . មាឃ | ខែទី ៣ | ស្វាព្រាម មាន២៩ ថ្ងៃ |
| . ផល្គុន | ខែទី ៤ | ក.បុព្វផល្គុណី គោឈ្មោល មាន៣០ ថ្ងៃ<br>ខ.ឧត្តរផល្គុណី គោញី |
| .ចេត្រ | ខែទី ៥ | ខ្លា មាន ២៩ ថ្ងៃ |
| . ពិសាខ | ខែទី ៦ | ក្របី មាន ៣០ ថ្ងៃ |

| | | |
|---|---|---|
| - ជេស្ឋ | ខែទី ៧ | ពពែ មាន ២៩ ថ្ងៃ |
| - អាសាឍ | ខែទី ៨ | ក.បុព្វាសាឍរាជសីហ៍ឈ្មោល |
| | | ខ.ឧត្តរាសាឍ រាជសីហ៍ញី មាន៣០ថ្ងៃ |
| - ស្រាពណ៍ | ខែទី ៩ | ផ្កាយឈើ រឺផ្កាយព្រឹក មាន ២៩ ថ្ងៃ |
| - ភទ្របទ | ខែទី ១០ | ក.បុព្វភទ្ទបទា រមាសឈ្មោល |
| | | ខ.ឧត្តរភទ្ទបទា រមាសញី មាន ២៩ ថ្ងៃ |
| - អស្សុជ | ខែទី ១១ | សេះ មាន ២៩ ថ្ងៃ |
| -កត្តិក | ខែទី ១២ | ក្ងានមាន់ មាន ៣០ ថ្ងៃ ។ |

**បញ្ជាក់ :**

បណ្ដាខែទាំង ១២នេះ មានខែ ៣ គឺ ផល្គុន,អាសាឍ, ភទ្របទ នៅក្នុងរចាប់ខែ មានឈ្មោះពីរ ១ ពីព្រោះអ្វី ?

ពីព្រោះខែទាំង ៣ នេះ បើរាសីចក្រវិលដល់ខែណា ឆ្នាំណា ឆ្នាំនោះ ត្រូវលើកខែនោះ ដើម្បីបង្គ្រប់ប្រតិទិន ។

ឧ-បើឆ្នាំណា រាសីចក្រវិលដល់ខែផល្គុន ឆ្នាំនោះត្រូវលើកខែផល្គុន។ ដូចនេះខែផល្គុនមាន ២ គឺ ផល្គុនមុន គេអោយ

ឈ្មោះថា បុព្វផល្គុណី, ផល្គុនក្រោយ គេអោយឈ្មោះថា ឧត្តរផល្គុណី ។

-បើឆ្នាំណា រាសីចក្រវិលដល់ខែអាសាឍ(១) ឆ្នាំនោះត្រូវលើកខែអាសាឍ ។ ដូចនេះ ខែអាសាឍមាន ២ គឺ ខែអាសាឍមុន គេអោយឈ្មោះថា បុព្វាសាឍ បច្ចុប្បន្នហៅ បឋមាសាឍ, ខែអាសាឍក្រោយ គេអោយឈ្មោះថា ឧត្តរាសាឍ បច្ចុប្បន្នហៅ ទុតិយាសាឍ ។

-បើឆ្នាំណា រាសីចក្រវិលដល់ខែភទ្របទ ឆ្នាំនោះត្រូវលើកខែភទ្របទ ។ ដូចនេះ ខែភទ្របទមាន ២ គឺ ភទ្របទមុន គេអោយឈ្មោះថា បុព្វភទ្ទបទា , ខែភទ្របទក្រោយ គេអោយឈ្មោះ ឧត្តរភទ្ទបទា ( មើលសុរិយាត្រឡើងស័ក ) ។

ពីបុរាណ លោកលើកខែ ៣ គឺផល្គុន,អាសាឍ,ភទ្របទ តែក្រោយមក លោកសំរេចអោយលើកខែ តែខែអាសាឍមួយប៉ុននោះ បើទុកជាការលើកខែនោះ មានខ្វះថ្ងៃ រឺ លើសថ្ងៃយ៉ាងណាក៏ដោយ ។

---

( ១ ) ពាក្យអាសាឍ្ហសរសេរបាន ៣ បែប : អាសាឍ អាសាឍ្ហ , អាសាធ

## ក.៣-របាប់ឆ្នាំ ១២

របាប់ឆ្នាំ តាមអរិយធម៌ខ្មែរ មានឈ្មោះ ១២

| | | |
|---|---|---|
| - ជូត | ឆ្នាំទី ១ | ឆ្នាំកណ្ដុរ |
| - ឆ្លូវ | ឆ្នាំទី ២ | ឆ្នាំគោ |
| - ខាល | ឆ្នាំទី ៣ | ឆ្នាំខ្លា |
| - ថោះ | ឆ្នាំទី ៤ | ឆ្នាំទន្សាយ |
| - រោង | ឆ្នាំទី ៥ | ឆ្នាំនាគ |
| - ម្សាញ់ | ឆ្នាំទី ៦ | ឆ្នាំពស់ |
| - មមី | ឆ្នាំទី ៧ | ឆ្នាំសេះ |
| - មមែ | ឆ្នាំទី ៨ | ឆ្នាំពពែ |
| - វក | ឆ្នាំទី ៩ | ឆ្នាំស្វា |
| - រកា | ឆ្នាំទី ១០ | ឆ្នាំមាន់ |
| - ច | ឆ្នាំទី ១១ | ឆ្នាំឆ្កែ |
| - កុរ | ឆ្នាំទី ១២ | ឆ្នាំជ្រូក ។ |

កំនត់សំគាល់ :

១.ឆ្នាំចន្ទគតិ មាន ៣៥៤ថ្ងៃ ។ តែរយៈពេល ៣ឆ្នាំ រឺ២ឆ្នាំ មានលើកខែម្តង។ រយៈពេល៤ រឺ ៥ឆ្នាំ មានលើកថ្ងៃម្តងតាម រាសីចក្រ ដើម្បីបង្គ្រប់ថ្ងៃប្រតិទិន ។

២.ការប្រៀបធៀបនៃការរាប់ថ្ងៃ ខែ ឆ្នាំ របស់ខ្មែរ និង ចិន, យួន,...

**របាប់ថ្ងៃរបស់ខ្មែរ**

**ក. របាប់ថ្ងៃ**

ការរាប់ថ្ងៃខ្មែរ :អាទិត្យ.ចន្ទ.អង្គារ.ពុធ.ព្រហស្បតិ៍.សុក្រ សៅរ៍,...

-របាប់ថ្ងៃរបស់ចិន : ចន្ទ.អង្គារ.ពុធ.ព្រហស្បតិ៍.សុក្រ,....

**ខ. របាប់ខែ**

- របាប់ខែរបស់ខ្មែរ : មិគសិរ.បុស្ស.មាឃ.ផល្គុន,...

-របាប់ខែរបស់ចិន.យួន,... គេយកថ្ងៃទី១ខែមាឃ របស់ ខ្មែរ ធ្វើជាថ្ងៃខែទី ១ ។ ប៉ុន្តែគេមិនរាប់ថា មិគសិរ.បុស្ស.

មាឃ,...ដូចខ្មែរទេ គឺគេរាប់ថា ខែ១,ខែ២,ខែ៣, ខែ៤,... វិញ។ តែខ្លះគេថា ខែ ក្ដាន់ , ក្ដាម, ស្វាព្រាម,... ។

### គ. របាប់ឆ្នាំ

- ការរាប់ឆ្នាំរបស់ខ្មែរ : ជូត,ឆ្លូវ,ខាល,ថោះ,...
- ការរាប់ឆ្នាំរបស់ចិនយួន : ឆ្នាំកណ្ដុរ,គោ,ខ្លា,ទន្សាយ,..

## II..របាប់តាមសុរិយគតិ

ខ្មែរថា របាប់តាមសុរិយគតិ តែអ្នកខ្លះថា របាប់តាមសកល ។ បើនិយាយអោយច្បាស់ របាប់សកលនេះ គឺជារបាប់តាមគ្រិស្តសាសនាសុទ្ធសាធ ។ ដោយគ្រិស្តសាសនាមាន សាវ័កនៅច្រើនប្រទេស គេនាំគ្នាអោយឈ្មោះរបាប់នេះថាជារបាប់សកលទៅវិញ ។ របាប់សកលនេះ បើតាមអរិយធម៌ ខ្មែរថា របាប់តាមសុរិយគតិ ។

### ក. របាប់តាមសុរិយគតិ

ក.១.របាប់តាមថ្ងៃសប្ដាហ៍

របាប់ថ្ងៃ: ចន្ទ.អង្គារ.ពុធ.ព្រហស្បតិ៍.សុក្រ.សៅរ៍.អាទិត្យ ។

ក.២.របាប់ខែ ១២

របាប់ខែ តាមសុរិយគតិ មាន :

| | | |
|---|---|---|
| - មករា | មករ | មាន ៣១ ថ្ងៃ |
| - កុម្ភៈ | ឆ្មាំង | មាន ២៨ រឺ ២៩ថ្ងៃ [១] |
| - មីនា | ត្រី | មាន៣១ ថ្ងៃ |
| - មេសា | ចៀម | មាន ៣០ ថ្ងៃ |
| - ឧសភា | គោឧសភរឺក្បាលគោ | មាន ៣១ ថ្ងៃ |
| - មិថុនា | គូបុរសនិងស្ត្រី | មាន ៣០ ថ្ងៃ |
| - កក្កដា | ក្ដាម | មាន ៣១ ថ្ងៃ |
| - សីហា | សីហៈ | មាន ៣១ ថ្ងៃ |
| - កញ្ញា | ស្រីក្រមុំ | មាន ៣០ ថ្ងៃ |
| - តុលា | ជញ្ជីង | មាន ៣១ ថ្ងៃ |
| - វិច្ឆិកា | ខ្ទួយ | មាន ៣០ ថ្ងៃ |
| - ធនុ | ធ្នូ | មាន ៣១ ថ្ងៃ |

១ឆ្នាំមាន ៣៦៥ រឺ ៣៦៦ ។

---

១) បើឆ្នាំណា មានចំនួនឆ្នាំចែកដាច់នឹង ៤ ឆ្នាំនោះ ខែកុម្ភៈមាន ២៩ថ្ងៃ

ក.៣.របាប់ឆ្នាំ

សុរិយគតិ គ្មានឈ្មោះឆ្នាំសំរាប់រាប់ដូចឆ្នាំចន្ទគតិទេ ។ លោករាប់ពីមួយ,ពីរ,បី...រហូតដល់ឆ្នាំបច្ចុប្បន្ន ឧ-ឆ្នាំម្យាញ់ ២០០១ ។

**កំនត់សំគាល់ :**

១.អំពីរបាប់ថ្ងៃ សប្តាហ៍

តាមចន្ទគតិ : អាទិត្យ,ចន្ទ,អង្គារ,ពុធ,...

តាមសុរិយគតិ : ចន្ទ,អង្គារ,ពុធ,ព្រហស្បតិ៍,...

២.អំពីរបាប់ខែ

តាមចន្ទគតិ : មិគសិរ,បុស្ស,មាឃ,...

តាមសុរិយគតិ : មករា,កុម្ភៈ,មីនា,...

៣.អំពីរបាប់ឆ្នាំ

តាមចន្ទគតិ : ជូត,ឆ្លូវ,ខាល,ថោះ,...

តាមសុរិយគតិ : ១,២,...១000,...២000,២00១,...

## អំពីស័ក និង ឆ្នាំ

បើតាមវិរិយធម៌ខ្មែរ ស័កមានឈ្មោះត្រឹមតែ១០ គឺឯកស័ក ទោស័ក,ត្រីស័ក,ចត្វាស័ក,បញ្ចស័ក,ឆស័ក , សប្តស័ក ,អដ្ឋស័ក, នពស័ក,និងសំរឹទ្ធិស័ក ។ តែឆ្នាំវិញមានឈ្មោះចំនួន ១២ គឺ ជូត, ឆ្លូវ,...។

## អំពីរាប់ស័ក និង ឆ្នាំ

ការរាប់ស័ក បានត្រឹមតែ ១០ គឺគេរាប់ពីឯកស័ក -ល- សំរឹទ្ធិស័ក គឺគេចាប់រាប់ត្រលប់ពីឯកស័ក,...ឡើងវិញ។ ឯឆ្នាំវិញ បើរាប់ឈ្មោះឆ្នាំមាន ១២ ។ តែបើរាប់ចំនួនឆ្នាំ ពីចំនួន១,២,... ដល់ម៉ឺន សែន លានឆ្នាំក៏ដោយ ក៏ស័កមានត្រឹមតែ១០ ប៉ុននោះ ឯង ។ ពីព្រោះ ស័ក សំរាប់សំគាល់លេខខាងចុង ពីចំនួន ១ ដល់១០ នៃព្រឹត្តិការណ៍ រឺ ហេតុអស្ចារ្យណាមួយប៉ុននោះ ។

ឧ-ប្រតិទិន ឆ្នាំម្សាញ់ ត្រីស័ក ( លេខ ៣នៅខាងចុង )

ឆ្នាំម្សាញ់ ព.ស. ២៥៤៥

គ.ស. ២០០១

ម.ស. ១៩២៣

ច.ស. ១៣៦៣

តើត្រីស័ក ដែលបានយកមកដាក់ក្នុងប្រតិទិននេះ ជាស័ករបស់ព្រឹត្តិការណ៍ណាមួយ ?

ពាក្យ " ត្រីស័ក" <( ត្រីៈ៣ + ស័កៈឆ្នាំ=ឆ្នាំ៣ រឺ ថាឆ្នាំដែលមានលេខ ៣នៅខាងចុង ) ។ តើព្រឹត្តិការណ៍ណាដែលមានលេខ ៣ នៅខាងចុង ?

យើងឃើញមានព្រឹត្តិការណ៍ ២ ដែលមានលេខ៣នៅចុង គឺ ម.ស.និង ច.ស. ។ សករាជទាំង ២ នេះ នៅក្នុងឆ្នាំម្សាញ់នេះ ថាជាត្រីស័កបានដូចគ្នា ។ តែបើយោងទៅលើប្រវត្តិនៃការបង្កើតស័ក ឃើញថា ស័ក កើតនៅក្នុងសម័យព្រះបាទព្រះកេតុមាលា បានឡើងសោយរាជ្យ ព្រះអង្គបានរក្សាសីល ៥ ចាំសីល៨ ខំប្រតិបត្តិតាមព្រះធម៌និងវិន័យ ប្រជានុរាស្ត្រ បានសេចក្ដីសុខសប្បាយណាស់ ។ ប្រជានុរាស្ត្របានតែងតាំងមហាសករាជពីឆ្នាំថោះ ពុទ្ធសករាជ ៦២៣ ។

ដូចនេះ ឆ្នាំម្សាញ់ " ត្រីស័ក" នេះ ជាស័ករបស់មហាសករាជ មិនមែនស័ករបស់ព្រឹត្តិការណ៍ណាមួយឡើយ។

ខ_ស្តីអំពីរបាប់

# ឯកវចនៈ,សតវចនៈ,សហស្សវចនៈ

ពាក្យទាំង ៣ ម៉ាត់ខាងលើនេះ ជាកន្សោមពាក្យមួយ ដែលមាននិយមន័យ ដាច់ដោយឡែកពីគ្នា មិនមានច្រលំគ្នាឡើយ ដូចជា

- ដំប សំគាល់ចំនួន " ៤ "

បើគេនិយាយថា ពីល្ងាចមិញ ខ្ញុំដកសំនាបបានចំនួន ៧ដំប គឺបាន ៤ x ៧ =២៨ កណ្តាប់ ។

- ផ្លូន = ១០ដំប , សំគាល់ចំនួន " ៤០ "

បើគេនិយាយថា ពីម្សិលមិញ ពួកកសិករដកសំនាបបាន ៣ផ្លូន ៥ដំប គឺបាន

*_ ៣ផ្លូន = ៤០ x ៣ = ១២០

*_ ៥ដំប = ៤ x ៥ = ២០

៣ផ្លូន ៥ដំប = ១៤០ កណ្តាប់ ។

- ស្លឹក = ១០ផ្លូន , សំគាល់ចំនួន ៤០០

បើគេនិយាយថា ពីល្វាចមិញ ខ្ញុំលើករវេទជកសំនាបបាន ២ស្លឹក ៤ ផ្លូន ៥ ដំប គឺបាន

*- ២ស្លឹក = ២ x ៤០០ = ៨០០

*- ៤ផ្លូន = ៤ x ៤០ = ១៦០

*- ៥ដំប = ៥ x ៤ = ២០

២ស្លឹក ៤ផ្លូន ៥ដំប គឺបាន ៩៨០ កណ្ដាប់ ។

- ទ្វាទសកវី ១ឡូ សំគាល់ចំនួន " ១២ "

ពីម្សិលមិញ ខ្ញុំទិញចាន ២៥ ឡូ ។

២៥ឡូ = ២៥ x ១២ = ៣០០ ចាន ។

យ៉ាងណាមិញ ពាក្យ ទសវត្ស.សតវត្ស.សហស្សវត្ស ក៏មានលក្ខណៈសំគាល់ដូចនោះដែរ ។

បញ្ជាក់ ៖

ពាក្យ ពុទ្ធសករាជ.គ្រិស្តសករាជ.មហាសករាជ យើងយកទៅប្រើលើព្រឹត្តិការណ៍ណាមួយក៏បាន ប៉ុន្តែ បើយកទៅប្រើលើព្រឹត្តិការណ៍ណា សូមប្រើអោយត្រូវតាមព្រឹត្តិការណ៍នោះ ។

ឧទាហរណ៍ ៖

- ព.ស.ចាប់គិតពីថ្ងៃ ១ រោច ខែពិសាខ ឆ្នាំម្សាញ់ ធ្វើជាថ្ងៃទី ១ នៃពុទ្ធសករាជ ។

- គ.ស.ចាប់គិតពីថ្ងៃទី ១ ខែ មករា ឆ្នាំរកា ធ្វើជាថ្ងៃទី១ នៃគ្រិស្តសករាជ ។

-ម.ស. ចាប់គិតពី ឆ្នាំថោះ[១] ធ្វើជាឆ្នាំទី ១ នៃមហាសករាជ ។

-ច.ស.ចាប់គិតពីថ្ងៃ ចន្ទ ១២កើត ខែចេត្រ ឆ្នាំកុរ ធ្វើជាថ្ងៃទី១ នៃចុល្លសករាជ ។

---

( ១ ) រកឯកសារថ្ងៃ និងខែ មិនទាន់បាន

ដោយយល់ឃើញថា ប្រជានុរាស្ត្រខ្មែរ នៅពេលបច្ចុប្បន្ននេះ កំពុងលង់ខ្លួនប្រើថ្ងៃ ខែ ឆ្នាំ របស់គ្រិស្តសាសនា ។ ដើម្បីអោយងាប់យល់. ខ្ញុំសូមលើកថ្ងៃ ខែ ឆ្នាំ របស់គ្រិស្តសាសនាមកធ្វើជាឧទាហរណ៍ ។

## ១‸ មេរៀនអំពីទសវត្ស

ពាក្យ "ទសវត្ស" <ទសៈ(១០ ).វច្ឆរ > វស្សរ > វស្សៈ (ឆ្នាំ )បានន័យថា ឆ្នាំ១០ រឺ ១០ឆ្នាំ ។

### គេចាប់រាប់ពី

- ថ្ងៃទី ១ ខែមករា ឆ្នាំរកាជាឆ្នាំ ទី១ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំមមីជាឆ្នាំទី១០ គេហៅថា ១ ទសវត្ស រឺ ទសវត្សទី ១ ។
- ថ្ងៃទី១ ខែ មករា ឆ្នាំមមែជាឆ្នាំទី១១ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំរោងជាឆ្នាំទី២០ គេហៅថា ២ទសវត្ស រឺ ទសវត្សទី២។
- ថ្ងៃទី ១ ខែមករា ឆ្នាំម្សាញ់ជាឆ្នាំទី ២១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំខាលជាឆ្នាំទី ៣០ គេហៅថា ៣ ទសវត្ស រឺ ទសវត្សទី៣ ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

-ថ្ងៃទី១ ខែមករា ឆ្នាំឆ្លូវជាឆ្នាំទី១០១ រហូតដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ចជាឆ្នាំទី១១០ គេហៅថា ១១ទសវត្ស រ៍ ទសវត្សទី ១១ ។

- ថ្ងៃទី ១ ខែមករា ឆ្នាំកុរជាឆ្នាំទី ១១១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំវកជាឆ្នាំទី ១២០ គេហៅថា ១២ ទសវត្ស រ៍ទសវត្សទី ១២ ។

-ថ្ងៃទី១ ខែ មករា ឆ្នាំរកាជាឆ្នាំទី១២១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំមមីជាឆ្នាំទី១៣០ គេហៅថា ១៣ ទសវត្ស រ៍ ទសវត្សទី ១៣ ។

-ល-

- ថ្ងៃទី១ ខែមករា ឆ្នាំម្សាញ់ ជាឆ្នាំទី២០១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំខាលជាឆ្នាំទី ២១០ គេហៅថា ២១ទសវត្ស រ៍ ទសវត្សទី ២១ ។

-ថ្ងៃទី១ ខែមករា ឆ្នាំថោះជាឆ្នាំទី២១១ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំជូតជាឆ្នាំទី ២២០ គេហៅថា ២២ ទសវត្ស រ៍ ទសវត្សទី ២២ ។

- ល -

-ថ្ងៃទី១ ខែមករា ឆ្នាំឆ្លូវជាឆ្នាំទី ១០០១ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំចជាឆ្នាំទី ១០១០ គេហៅថា ១០១ ទសវត្ស រឺ ទសវត្សទី១០១ ។

ថ្ងៃទី១ ខែមករា ឆ្នាំកុរ ជាឆ្នាំទី ១០១១ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំវក ទី ១០២០ គេហៅថា ១០២ ទសវត្ស រឺ ទសវត្សទី១០២។

- ល -

-ថ្ងៃទី១ ខែមករា ឆ្នាំម្សាញ់ ជាឆ្នាំទី ២០០១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំខាលជាឆ្នាំទី ២០១០ គេហៅថា ២០១ ទសវត្ស រឺ ទសវត្សទី ២០១ ។

-ថ្ងៃទី១ ខែមករា ឆ្នាំថោះជាឆ្នាំទី ២០១១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំជូតជាឆ្នាំទី ២០២០ គេហៅថា ២០២ ទសវត្ស រឺ ទសវត្សទី ២០២ ។

បញ្ជាក់ ៖

- បើយើងគិតតាម គ.ស. សព្វថ្ងៃស្ថិតនៅក្នុងទសវត្ស ២០១ ។

- បើយើងប្រើទសវត្ស អោយស្រួលគេយល់ គឺយើងប្រើត្រឹមតែ ១០ ទសវត្ស :

ឧ.ក.១.កូនស្រីពៅរបស់ខ្ញុំ បានកើតនៅក្នុងទសវត្សទី ៩ នៃសតវត្សទី ២០ ( កើតឆ្នាំ ១៩៨១-៩០ ) ។

ក.២.ខ្ញុំសរសេរសៀវភៅនេះ នៅក្នុងទសវត្សទី១ នៃសតវត្សទី ២១ រឺនៅទសវត្សទី១ ដើមសហស្សវត្សទី៣ ( ២០០១-២០១០ ) ។

## ២- មេរៀនអំពីសតវត្ស

ពាក្យ សតវត្ស <សតៈ (១០០ )+វច្ឆរ > វស្សៈ (ឆ្នាំ ) បានន័យថា ១០០ឆ្នាំ រឺ ឆ្នាំ ១០០ ។ សតវត្ស គេចាប់រាប់ពីថ្ងៃទី១ ដែលគេ បានកំនត់យក រហូតដល់ថ្ងៃដាច់ឆ្នាំទី ១០០ នៃព្រឹត្តិការណ៍នោះ ។

ឧទាហរណ៍ រាប់តាមឆ្នាំគ្រីស្តសករាជ

**គេចាប់រាប់ពី :**

- ថ្ងៃទី១ ខែមករា ឆ្នាំរកា ជាឆ្នាំទី១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំជូតជាឆ្នាំទី ១០០ គេហៅថា ១សតវត្សរ៍សតវត្សទី១ ។

-ថ្ងៃទី១ ខែមករា ឆ្នាំឆ្លូវជាឆ្នាំទី១០១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំរោង ជាឆ្នាំទី ២០០ គេហៅថា ២ សតវត្សរ៍ សតវត្សទី ២ ។

-ថ្ងៃទី១ ខែមករា ឆ្នាំម្សាញ់ ជាឆ្នាំទី២០១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំវក ជាឆ្នាំទី ៣០០ គេហៅថា ៣ សតវត្សរ៍ សតវត្សទី ៣។

- ល -

-ថ្ងៃទី១ ខែមករា ឆ្នាំឆ្លូវជាឆ្នាំទី ១០០១ រហូតដល់ថ្ងៃទី ៣១ខែ ធ្នូ ឆ្នាំរោងជាឆ្នាំទី ១១០០ គេហៅថា ១១សតវត្សរ៍ សតវត្សទី ១១ ។

-ថ្ងៃទី១ ខែមករា ឆ្នាំម្សាញ់ ទី១១០១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំវក ទី១២០០ គេហៅថា ១២ សតវត្សរ៍ សតវត្សទី១២។

- ល -

-ថ្ងៃទី១ ខែមករា ឆ្នាំឆ្លូវ ទី ១៩០១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំរោង ទី២០០០ គេហៅថា ២០សតវត្សរ៍សតវត្សទី២០។

-ថ្ងៃទី១ ខែមករា ឆ្នាំម្សាញ់ ទី២០០១ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំវក ទី ២១០០ គេហៅថា ២១សតវត្ស រឺ សតវត្សទី២១។

## ៣.មេរៀនអំពីសហស្សវត្ស

ពាក្យ សហស្សវត្ស <សហស្ស:(១000 )+វច្ឆ>វស្ស>វត្ស (ឆ្នាំ ) មានន័យថា ១000 ឆ្នាំ រឺ ឆ្នាំ១000 ។ សហស្សវត្ស គេចាប់ រាប់ពីថ្ងៃទី១ នៃព្រឹត្តិការណ៍ ដែលគេបានកំនត់យក រហូតដល់ថ្ងៃ ដាច់ឆ្នាំទី ១000 នៃព្រឹត្តិការណ៍នោះ ។

ឧទាហរណ៍ រាប់តាមឆ្នាំគ្រិស្តសករាជ

### គេចាប់រាប់ពី :

-ថ្ងៃទី១ ខែមករា ឆ្នាំរកាជាឆ្នាំទី១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំជូតជាឆ្នាំទី ១000 គេហៅថា ១ សហស្សវត្ស រឺ សហស្សវត្ស ទី ១ ។

-ថ្ងៃទី១ ខែមករា ឆ្នាំឆ្លូវជាឆ្នាំទី១00១ រហូតដល់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំរោងជាឆ្នាំទី ២000 គេហៅថា ២ សហស្សវត្ស រឺ សហស្សវត្ស ទី ២ ។

-ថ្ងៃទី១ ខែមករា ឆ្នាំម្សាញ់ ជាឆ្នាំទី២០០១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំវកជាឆ្នាំទី ៣០០០ គេហៅថា ៣ សហស្សវត្ស រឺ សហស្សវត្ស ទី ៣ ។ ....

**ការសង្កេត :**

បើយើងចង់ដឹងថា នៅសម័យបច្ចុប្បន្ន ព្រឹត្តិការណ៍ណាមានប៉ុន្មានទសវត្ស , សតវត្ស , សហស្សវត្ស យើងយកចំនួនឆ្នាំព្រឹត្តិការណ៍នោះ ទៅចែកនឹង ១០,១០០,១០០០. ។

ឧទាហរណ៍ទី ១ : ពីទសវត្ស

-ព.ស. $\frac{២៥៤៥}{១០}$ = ២៤៥.៥ បច្ចុប្បន្នចូលទ.វ ទី ២៤៦

-គ.ស. $\frac{២០០២}{១០}$ = ២០០.២ បច្ចុប្បន្នចូលទ.វ ទី២០១

-ម.ស. $\frac{១៩២៣}{១០}$ = ១៩២.៣ បច្ចុប្បន្នចូលទ.វ ទី១៩៣

- ច.ស. $\frac{១៣៦៣}{១០}$ = ១៣៦.៣ បច្ចុប្បន្នចូលទ.វ ទី ១៣៧

## ១.២.ពីសតវត្ស

- ព.ស. $\frac{២៥៤៥}{១០០}$ = ២៥,៤៥ បច្ចុប្បន្នចូលស.វ ទី ២៦

- គ.ស. $\frac{២០០២}{១០០}$ = ២០,០២ បច្ចុប្បន្នចូលស.វ ទី ២១

- ម.ស. $\frac{១៩២៣}{១០០}$ = ១៩,២៣ បច្ចុប្បន្នចូលស.វ ទី ២០

- ច.ស. $\frac{១៣៦៣}{១០០}$ = ១៣,៦៣ បច្ចុប្បន្នចូលស.វ ទី ១៤

## ១.៣.ពីសហស្សវត្ស

- ព.ស. $\frac{២៥៤៥}{១០០០}$ ២,៥៤៥ បច្ចុប្បន្នចូលសហ.វ ទី ៣

- គ.ស. $\frac{២០០២}{១០០០}$ = ២.០០២ បច្ចុប្បន្នចូលសហ.វ ទី ៣

- ម.ស. ១៩២៣/១០០០ = ១.៩២៣ បច្ចុប្បន្នចូលសហ.វ ទី ២

- ច.ស. ~~១៩២៣~~ 1363/១០០០ = ១.៣៦៣ បច្ចុប្បន្នចូលសហ.វ ទី ២

## ក. អំពីការប្រើទសវត្ស

តាមទស្សនៈផ្ទាល់ខ្លួន

បើយោងទៅតាមមេរៀនខាងលើ ខ្ញុំយល់ថា ការប្រើពាក្យ" ទសវត្ស " សព្វថ្ងៃនេះ មិនសមស្របនឹងមេរៀនខាងលើនេះឡើយ ឧ.ខ្ញុំសរសេរសៀវភៅនេះ នៅទសវត្ស៧០ រឺ ថានៅទសវត្សឆ្នាំ ៧០ តើទសវត្ស៧០ រឺ ទសវត្សឆ្នាំ ៧០ សំគាល់អ្វី ?

សូមជួយពិចារណា ការប្រើពាក្យទសវត្ស

ខ្ញុំសូមលើកឧទាហរណ៍ ប្រៀបធៀប :

- ខ្ញុំដកសំនាបបាន ដំប៥ រឺ ៥ដំប, តើខ្ញុំដកសំនាបបាន ប៉ុន្មានកណ្តាប់ ?

- ខ្ញុំទិញចាន ២ ទ្វាទសក រឺ ២ឡូ. តើខ្ញុំទិញចានបាន ប៉ុន្មាន ?

- ខ្ញុំយកសំនាបបាន ២ផ្លូន . តើខ្ញុំយកសំនាបបានប៉ុន្មានកណ្ដាប់ ?

- ខ្ញុំទិញផ្លែមង្ឃុត ២ស្លឹក .តើខ្ញុំទិញផ្លែមង្ឃុតបានប៉ុន្មានផ្លែ ?

**បញ្ជាក់ : ចំលើយ**

- ផំប ៥ x ៤ = ២០ កណ្ដាប់

- ឡូ ២ x ១២ = ២៤ ចាន

- ផ្លូន ២ x ៤០ = ៨០ កណ្ដាប់

- ស្លឹក ២ x ៤០០ = ៨០០ ផ្លែ

យ៉ាងណាមិញ ទសវត្សរ៍៧០ រឺ ទសវត្សរ៍ឆ្នាំ ៧០ ក៏មានលក្ខណៈ ដូចខាងលើនេះដែរ

ទសវត្សរ៍៧០ = ១០ x ៧០ = ៧០០ ឆ្នាំ

រយៈពេល ៧០០ឆ្នាំ រឺ ឆ្នាំ ៧០០ ទៅពិនិត្យលើសករាជដែលមានប្រើនៅក្នុងលោកទាំងអស់ គ្មានសករាជណា មានរយៈពេល ៧០០ ឆ្នាំទេ ។ តែបើប្រើយោលទៅលើគ្រិស្តសករាជតើអ្នកប្រើសំគាល់បែបណា ?

តាមឧទាហរណ៍ខាងលើនេះខ្ញុំយល់ថា

១. បើយើងប្រើសំគាល់ទី ចាំបាច់ប្រើពាក្យទសវត្សធ្វើអ្វី យើងប្រើថា នៅឆ្នាំ៧០នៃសតវត្សទី ២០ ខ្ញុំបានសរសេរសៀវភៅ ៣ ក្បាល ។

២. បើយើងប្រើសំគាល់រយៈពេល ១០ឆ្នាំ យើងត្រូវប្រើពាក្យថា :

ខ្ញុំបានសរសេរសៀវភៅ នៅទសវត្ស ៧ រឺ ទសវត្សទី ៧ នៃសតវត្សទី២០ ( ១៩៦១_៧០ ) ។

_ ខ្ញុំបានកើតនៅទសវត្ស៣ រឺ ទសវត្សទី៣ នៃសតវត្សទី ២០ ( ១៩២១_៣០ ) ។

_ ម្ដាយខ្ញុំគាត់បានស្លាប់ នៅទសវត្ស៨ រឺ ទសវត្សទី ៨ នៃសតវត្សទី ២០ ( ១៩៧១_ ៨០ ) ។

បើយើងយល់បែបដូចនេះហើយ យើងសរសេរ រឺនិយាយបែបដូចនេះបាន យើងលែងនិយាយតាមគ្នា រឺ លែងច្រលំន័យនៃការប្រើពាក្យ " ទសវត្ស " ទៀតឡើយ ។

## ខ. អំពីការប្រើសតវត្ស រឺ សហស្សវត្ស

បើយោលទៅតាមមេរៀន

សតវត្សទី២០ ចាប់គិតពីថ្ងៃទី១ ខែមករា ឆ្នាំឆ្លូវជាឆ្នាំទី ១៩០១ រហូតដល់ថ្ងៃទី ៣១ធ្នូ ឆ្នាំរោងជាឆ្នាំ ទី ២០០០ ។

សតវត្សទី ២១ ចាប់គិតពីថ្ងៃទី ១ ខែ មករា ឆ្នាំម្សាញ់ ជាឆ្នាំទី២០០១ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំវកជាឆ្នាំទី ២១០០ ។

សហស្សវត្សទី ១ ចាប់គិតពីថ្ងៃទី ១ ខែ មករា ឆ្នាំ រកា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំជូតជាឆ្នាំ ទី ១០០០ ។

សហស្សវត្សទី ២ ចាប់គិតពីថ្ងៃទី ១ ខែ មករា ឆ្នាំឆ្លូវជា ឆ្នាំទី ១០០១ រហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំរោងជាឆ្នាំ ទី ២០០០ ។

សហស្សវត្សទី ៣ ចាប់គិតពីថ្ងៃទី ១ ខែ មករា ឆ្នាំម្សាញ់ ជាឆ្នាំទី ២០០១ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំវកជាឆ្នាំទី ៣០០០ ។

## ការពិចារណា

នៅពេលដែលយើងធ្វើបុណ្យ...សតវត្សទី២០ ឈានចូលដល់សហស្សវត្សថ្មី....រយៈពេល ៣ ថ្ងៃចាប់ពីថ្ងៃទី ៣០-.៣១ ឆ្នាំ ១៩៩៩ ដែលជាថ្ងៃបិទ សតវត្សទី ២០ និងដល់ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០០ ជាថ្ងៃចាប់ផ្ដើមបើកសតវត្សទី ២១,...។

( រាជរដ្ឋាភិបាលកម្ពុជា លេខ ០៧ សរណោន )

សូមជួយពិចារណា តើកថាខណ្ឌខាងលើនេះត្រូវ មេរៀនខុស រឺ មេរៀនត្រូវ កថាខណ្ឌខាងលើនេះខុស ?

## ការសន្និដ្ឋាន

- បើនិយាយពីសតវត្ស នៅឆ្នាំរោងជាឆ្នាំទី ២០០០ ជាឆ្នាំចុង ក្រោយនៃសតវត្សទី ២០ ទើបចូលបាន ១ ថ្ងៃ ។
- បើនិយាយពីសហស្សវត្ស នៅខ្វះ ១ឆ្នាំពេញ ។

### គ. ស្តីអំពីរបាប់

## រកអាយុ និង រកឆ្នាំកំណើត

បុរាណាចារ្យ លោកបានចងក្រងក្បួន សំរាប់រាប់រកអាយុ រឺសំរាប់រាប់រកឆ្នាំ របស់មនុស្ស រឺព្រឹត្តិការណ៍ណាមួយ ។

### ១.ក្បួនរបាប់រកអាយុ

ដោយយល់ឃើញថា បើរាប់ត្រឹមចំនួន ២០ ជាការងាយស្រួល តែបើរាប់ពីចំនួន ៣០,៤០,៥០,..,..១២៥,១៣២,១៤៣,... ២២៣,៣៣២,....១៩៤២,២០០២,.... ជាការលំបាកណាស់ ។

ឧ-១.លោក ម៉ុក គាត់មានកំនើតពីឆ្នាំ ឆ្លូវ សព្វថ្ងៃគាត់មានអាយុ រវាង ៦០ឆ្នាំ បច្ចុប្បន្នឆ្នាំម្សាញ់ តើសព្វថ្ងៃគាត់មានអាយុប៉ុន្មាន ?

- អាយុរវាង ៦០ លោកអោយរាប់ចំនួន ១២

១. ឆ្លូវ, ២. ខាល, ៣.ថោះ, ៤.រោង , ៥.ម្សាញ់, ៦.មមី, ៧.មមែ, ៨.វក, ៩.រកា, ១០.ច, ១១.កុរ, ១២.ជូត។

បើរាប់ពីឆ្នាំឆ្លូវមកដល់ឆ្នាំជូត គាត់មានអាយុ ៦០ឆ្នាំ បើរាប់មកដល់ឆ្នាំម្សាញ់ ជាឆ្នាំបច្ចុប្បន្ន គាត់មាន អាយុ ៦៥ ឆ្នាំ ។

ឧ-២.លោកតាសៅ គាត់មានកំនើតពីឆ្នាំ ខាល សព្វថ្ងៃគាត់មានអាយុរវាង ៨០ឆ្នាំ បច្ចុប្បន្នឆ្នាំម្សាញ់ តើលោកតាសៅគាត់មានអាយុប៉ុន្មាន ?

- អាយុរវាង ៨០ឆ្នាំ លោកអោយរាប់ចំនួន ៨

១. ខាល , ២.ថោះ ,៣. រោង,៤.ម្សាញ់,៥.មមី,៦.មមែ,៧.វក,៨.រកា ។

បើរាប់មកដល់ឆ្នាំរកា គាត់មានអាយុ ៨០ ឆ្នាំគត់ ។ បើបន្ត ១.ច, ២.កុរ ,៣.ជូត ,៤.ឆ្លូវ , ៥.ខាល,៦.ថោះ, ៧.រោង ,៨.ម្សាញ់ ជាឆ្នាំបច្ចុប្បន្ន គាត់មានអាយុ ៨៨ ឆ្នាំ ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY

ដូចនេះ លោកចងក្បួន ធ្វើការរាប់អោយមានចំនួនតិចហើយ បានត្រឹមត្រូវ ។

## ក-របាប់រកអាយុ

បើគេដឹងឆ្នាំកំនើត និង រវាងអាយុ

**លក្ខណៈទី១** : ចាប់ពីមួយឆ្នាំដល់មួយរយឆ្នាំ

- មនុស្សមានអាយុពី ១ ឆ្នាំដល់ ១៩ ឆ្នាំត្រូវរាប់ធម្មតា
- មនុស្សមានអាយុ រវាង ២០ អោយរាប់ ៨
- មនុស្សមានអាយុ រវាង ៣០ អោយរាប់ ៦
- មនុស្សមានអាយុ រវាង ៤០ អោយរាប់ ៤
- មនុស្សមានអាយុ រវាង ៥០ អោយរាប់ ២
- មនុស្សមានអាយុ រវាង ៦០ អោយរាប់ ១២
- មនុស្សមានអាយុ រវាង ៧០ អោយរាប់ ១០
- មនុស្សមានអាយុ រវាង ៨០ អោយរាប់ ៨
- មនុស្សមានអាយុ រវាង ៩០ អោយរាប់ ៦
- មនុស្សមានអាយុ រវាង ១០០ អោយរាប់ ៤

## លក្ខណៈទី២ : ចាប់រាប់ពី១០១ឆ្នាំដល់១០០០ឆ្នាំ

ព្រះពុទ្ធសករាជ ចាប់រាប់ពីថ្ងៃ ១រោចខែពិសាខ ឆ្នាំម្សាញ់ រហូតដល់ថ្ងៃ ១៥កើត ខែពិសាខ ឆ្នាំមមី ទើបគ្រប់ ១ឆ្នាំ ពុទ្ធសករាជ ។ ដូចនេះ មួយឆ្នាំពុទ្ធសករាជ មានពីរឆ្នាំខ្មែរ គឺម្សាញ់ និង មមី,..... ។

ជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃ១រោច ខែពិសាខជា ថ្ងៃដើមឆ្នាំពុទ្ធសករាជ ។

ខ្ញុំសូមលើកយកពុទ្ធសករាជ មកធ្វើជាឧទាហរណ៍

### រយៈពេល ១២៥ ឆ្នាំ

១០០អោយរាប់ ៤, ២០អោយរាប់៨,ចំនួន៥អោយរាប់៥ ។

៤ + ៨ + ៥ = ១៧ អោយរាប់ ១៧ វី រាប់ ៥ ។

យើងចាប់រាប់ឆ្នាំម្សាញ់ រហូតដល់ឆ្នាំរកា៖ ( ១៧ វី ៥) មានរយៈពេល ១២៥ ឆ្នាំ នៅឆ្នាំរកា ។

### រយៈពេល ១៣២ ឆ្នាំ

១០០ អោយរាប់៤, ៣០អោយ៦, ចំនួន២ អោយ រាប់២

៤ + ៦ + ២ = ១២ អោយរាប់ ១២

យើងចាប់រាប់ពីឆ្នាំម្សាញ់ រហូតដល់ឆ្នាំរោង, មានរយៈពេល ១៣២ឆ្នាំ នៅឆ្នាំរោង ។

**រយៈពេល ១៤៣ ឆ្នាំ**

១០០អោយរាប់៤, ៤០អោយរាប់៤, ចំនួន៣ អោយរាប់៣

៤ + ៤ + ៣ = ១១ ,អោយរាប់ ១១

យើងចាប់រាប់ពីឆ្នាំម្សាញ់រហូតដល់ឆ្នាំថោះ . មានរយៈពេល ១៤៣ឆ្នាំ នៅឆ្នាំថោះ ។

**រយៈពេល ២២៣ ឆ្នាំ**

១០០អោយរាប់៤, បើ ២០០ អោយយក (៤x២) =៨, ២០ អោយរាប់ ៨ + ចំនួន ៣ អោយរាប់ ៣ ។

( ៤x ២ ) + ៨ + ៣ = ១៩ អោយរាប់ ១៩ រឺ ៧

យើងរាប់ពីឆ្នាំម្សាញ់ រហូតដល់ឆ្នាំកុរ, មានរយៈពេល ២២៣ឆ្នាំ នៅឆ្នាំកុរ ។

**រយៈពេល ៣៣២ ឆ្នាំ**

១០០ អោយរាប់ ៤ . បើ ៣០០ អោយ ៤ x ៣=១២. ៣០ អោយរាប់ ៦. ចំនួន២ អោយរាប់ ២ ។

(៤ x ៣) + ៦ + ២ = ២០ =៨ អោយរាប់ ៨

យើងចាប់រាប់ពីឆ្នាំម្សាញ់ រហូតដល់ឆ្នាំជូត.មានរយៈពេល ៣៣២ឆ្នាំ នៅឆ្នាំជូត ។

**លក្ខណៈទី៣:** ចាប់រាប់ពី១០០១ដល់ ១០ ០០០

**រយៈពេល ១៩៤២ ឆ្នាំ**

១០០០ អោយរាប់៤ ,១០០អោយរាប់៤ បើ៩០០. យក (៤ x ៩) = ៣៦. ៤០អោយរាប់ ៤ .ចំនួន២ អោយរាប់ ២ ។

៤ + ៣៦ + ៤ + ២ = ៤៦ = ៤ + ៦ = ១០

យើងចាប់រាប់ពីឆ្នាំម្សាញ់ រហូតដល់ឆ្នាំខាល.មានរយៈពេល ១៩៤២ឆ្នាំ នៅឆ្នាំខាល ។

**រយៈពេល ២០០២ ឆ្នាំ**

១០០០ អោយរាប់៤. បើពីរពាន់ ៤ x ២ =៨ ចំនួន ២ អោយរាប់ ២ ។

( ៤ x ២ ) +២ = ១០ ( ពោយរាប់ ១០ )។

យើងចាប់រាប់ឆ្នាំម្សាញ់ រហូតដល់ឆ្នាំខាល , មានរយៈពេល ២០០២ឆ្នាំ, នៅឆ្នាំខាល

បើយើងគិតតាមគ្រិស្តសករាជ, យើងចាប់រាប់ពីឆ្នាំ រកា រហូតដល់ឆ្នាំមមី, មានរយៈពេល ២០០២ នៅឆ្នាំ មមី ។

## ខ. វិធីរាប់រកឆ្នាំកំណើត

### ក. របាប់រកឆ្នាំកំណើតបែបទី ១

បើគេដឹងអាយុពិតប្រាកដ គេចង់ដឹងឆ្នាំកំណើត គេត្រូវលាបាតដៃឆ្វេងគេឃើញ :

១. ម្រាមដៃប្រាំ គឺមេដៃ, ចង្អុលដៃ, ចង្អុលខ្មោច, នាងដៃ និង កូនដៃ ។

២. នៅតាមម្រាមដៃនីមួយៗ លើកលែងតែមេដៃចេញ មានសន្ធាក់បីៗ មានបួនៗនិងចុងម្រាម ។

បើយើងរាប់ជុំវិញ តាមសន្ធាក់ និងចុងម្រាម នៃម្រាមដៃទាំង ៤ ។

៣. យើងឃើញមានចំនុច ១២ ។ ចំនុចទាំង ១២ នេះ ជាតំនាងឆ្នាំទាំង ១២ ដែរ ។

៤. លោកចងក្រងជាក្បួនមានច្រើនបែប តែខ្ញុំមិនបាន យកតាមច្រើនបែបមកសរសេរទេ គឺយកតែពីរបែបដូចខាងក្រោម :




## គោរាប់បាតដៃបែបទី ១

. យើងដាក់លេខ ១០ត្រង់គល់សន្ធាកទី២នៃ ម្រាមកូនដៃ ។

. យើងដាក់លេខ ២០ នៅត្រង់ចុងម្រាមកូនដៃ ។

.យើងដាក់លេខ៣០ នៅត្រង់ចុងម្រាមចង្អុលខ្នាច ។

-យើងដាក់លេខ៤០ នៅត្រង់សន្ទាក់ទី៣ នៃម្រាមចង្អុលដៃ។

- យើងដាក់លេខ ៥០ នៅត្រង់គល់សន្ទាក់ម្រាមចង្អុលដៃ។

- យើងដាក់លេខ ៦០ នៅត្រង់គល់សន្ទាក់ម្រាម នាងដៃ។

-យើងដាក់លេខ៧០ នៅត្រង់គល់សន្ទាក់ទី២នៃម្រាមកូនដៃ។

- យើងដាក់លេខ ៨០ នៅត្រង់ចុងម្រាមកូនដៃ ។.

-យើងដាក់លេខ ៩០នៅត្រង់ចុងម្រាមចង្អុលខ្មោច ។

-យើងដាក់លេខ ១០០ នៅត្រង់សន្ទាក់ទី៣ នៃម្រាមចង្អុលដៃ ។

-យើងដាក់ឆ្នាំចប្ចុប្បន្ន នៅត្រង់គល់ម្រាមចង្អុលខ្មោច ។

ឧ-១.យុវជនសុខ មានអាយុ២៨ឆ្នាំ បើរាប់មកដល់ឆ្នាំមមី ជាឆ្នាំបច្ចុប្បន្ន ។ តើយុវជន សុខ មានកំណើតពី ឆ្នាំណា ?

- យើងដឹងថាលេខ ២០ នៅត្រង់ចុងម្រាមកូនដៃ ។ យើងចាប់រាប់បញ្ច្រាសពីសន្ទាក់ទី ៣.២.១...រហូតដល់លេខ៨. យើងកត់ចំណាំ នៅត្រង់ចំនុចនោះ ហើយយើងចាប់រាប់ពីឆ្នាំបច្ចុប្បន្នៈមមី.មមែ.វក.រកា.....រហូតដល់កន្លែងកត់ចំណាំនោះជាឆ្នាំអ្វី. យុវជនសុខ មានកំណើត ពីឆ្នាំនោះឯង ។

យុវជន សុខ មានកំណើតពីឆ្នាំថោះ ។

៦.២.ឧបាសក លី សុវីរ មានអាយុ ៧៥ឆ្នាំ បើរាប់មកដល់ឆ្នាំមមី ជាឆ្នាំបច្ចុប្បន្ន ។ តើឧបាសក លី សុវីរ មានកំណើតពីឆ្នាំណា ?

យើងដឹងថាលេខ ៧០ នៅត្រង់គល់សន្ធាក់ទី២ នៃម្រាមកូនដៃ។យើងចាប់រាប់ពីគល់សន្ធាក់កូនដៃ,គល់សន្ធាក់នាងដៃ,... .បើរាប់អស់លេខ៥ នៅត្រង់ចំនុចណា យើងកត់ចំនាំទុក ។ យើងចាប់រាប់ពីឆ្នាំបច្ចុប្បន្ន មមី,មមែ,វក,...រហូតដល់ចំនុចកត់ចំនាំនោះ ជាឆ្នាំអ្វី?ឧបាសក លី សុវីរ មានកំណើតពីឆ្នាំនោះឯង។

ឧបាសក លី សុវីរ មានកំណើតពីឆ្នាំរោង ។

## គេរាប់ធាតដៃបែបទី២

គេរាប់ ១០ នៅចុងម្រាមចង្អុលដៃ,គេរាប់២០ នៅចុងម្រាមនាងដៃ,....គឺចាប់រាប់វិលឯមួយៗ រហូតដល់អស់ចំនួនរវាងអាយុ ។ បើមានចំនួនឆ្នាំលើស ចំនួនរវាង ទើបគេរាប់បញ្រ្ចាសថយក្រោយវិញ រហូតដល់គ្រប់អាយុ ។




គេចាប់រាប់ពីឆ្នាំបច្ចុប្បន្ន ពីគល់សន្ទាក់ចង្អុលដៃទៅគល់សន្ទាក់ទី២ នៃម្រាមចង្អុលដៃ ។ បើរស់នៅត្រង់ណា ចំនុចនោះជាឆ្នាំកំនើត ។

ឧ.១.យុវជន សុខុម មានអាយុ ២២ នៅឆ្នាំមមី ។ តើយុវជន សុខុម មានកំនើតពីឆ្នាំណា ?

គេចាប់រាប់១០ នៅចុងម្រាមចង្អុលដៃ គេរាប់២០ នៅចុងម្រាមនាងដៃ.គេរាប់វិលឯមួយ ១ រហូតដល់អាយុវវាង ទើបគេរាប់បញ្ច្រាសថយក្រោយវិញ ដល់អស់អាយុ ។

យុវជន សុខុម មានអាយុ២០ នៅត្រង់ចុងម្រាមនាងដៃ។ គេចាប់រាប់បន្ថយ ១ នៅចុងម្រាមចង្អុលខ្នោច.២ នៅចុងម្រាមចង្អុលដៃ ។

គេចាប់រាប់ពីឆ្នាំបច្ចុប្បន្ន មមីនៅត្រង់គល់សន្ធាក់ទី ១ ម្រាមចង្អុលដៃ. ២មមែ នៅគល់សន្ធាក់ទី២ ម្រាមចង្អុលដៃ ៣.វក នៅត្រង់សន្ធាក់ទី ៣ ម្រាមចង្អុលដៃ . ៤.រកា នៅត្រង់ចុងម្រាមចង្អុលដៃ ។

ដូចនេះ យុវជន សុខុម មានកំនើតពីឆ្នាំរកា ។

ឧ.២.ឧបាសក សៅ មានអាយុ ៥៣ឆ្នាំ នៅឆ្នាំមមី ។ តើឧបាសក សៅ មានកំនើតពីឆ្នាំណា ?

បើរាប់ ១០, ២០, ៣០ .៤០ .៥០, អាយុ ៥០ មកស្ថិតនៅត្រង់គល់ម្រាមចង្អុលខ្នោច ។ នៅ ៣ឆ្នាំទៀតត្រូវរាប់បញ្ច្រាស ១, ២, ៣, មកត្រង់គល់សន្ធាក់ទី២ ម្រាមកូនដៃ ។

យើងរាប់ពីគល់សន្ទាក់ម្រាមចង្អុលដៃ មមី គល់សន្ទាក់ម្រាមចង្អុលដៃទី២.មមែ.៣-វក,.. មកដល់គល់សន្ទាក់ទី២ ម្រាមកូនដៃ ខាល ។

ដូចនេះ យុវជន សៅ មានកំនើតពីឆ្នាំ ខាល ។

**បញ្ជាក់** : បើយើងដាក់លេខ ១០ នៅត្រង់សន្ទាក់ទី ៣ នៃម្រាមចង្អុលដៃ.លេខ២០ នៅត្រង់ចុងម្រាមចង្អុលខ្មោច.... យើងដាក់ឆ្នាំបច្ចុប្បន្ននៅត្រង់គល់សន្ទាក់ម្រាមចង្អុលខ្មោច ដូចបែបទី ១ ដែរ ។

## ខ.វិធីរាប់រកឆ្នាំកំណើតបែបទី២

របាប់រកឆ្នាំកំនើតខាងលើ ងាយស្រួលតែមានចំនួនតិចជាង ១០០ បើមានចំនួនច្រើនជាង ១០០ មានភាពលំបាកណាស់ ។ ដូចនេះ ខ្ញុំនឹងលើកក្បួន១បែបទៀតដែលមានភាពងាយស្រួលមកបង្ហាញជូន ដូចតទៅ ។

# សរសេរលេខតំនាងឆ្នាំ

១- តំនាងឆ្នាំជូត

២-តំនាងឆ្នាំ ឆ្លូវ

៣- តំនាងឆ្នាំ ខាល

៤- តំនាងឆ្នាំ ថោះ

៥-តំនាងឆ្នាំ រោង

៦-តំនាងឆ្នាំ ម្សាញ់

៧- តំនាងឆ្នាំ មមី

៨-តំនាងឆ្នាំ មមែ

៩-តំនាងឆ្នាំ វក

១០-តំនាងឆ្នាំ រកា

១១-តំនាងឆ្នាំ ច

១២-តំនាងឆ្នាំ កុរ



បញ្ជាក់ ៖ បើបច្ចុប្បន្ន ជាឆ្នាំអ្វី យើងត្រូវយកឆ្នាំនោះមកធ្វើជាគោល

ឧ.១.មមី. យកលេខ ៧ មកធ្វើជា គោល

២. មមែ យកលេខ ៨ មកធ្វើជាគោល,.....។

ឧ.១.ឧបាសក លី សុវីរ មានអាយុ ៧៥ឆ្នាំ នៅឆ្នាំ មមី ។ តើឧបាសក លី សុវីរ មានកំណើតពីឆ្នាំណា ?

យើងយកអាយុ ៧៥ ចែកនឹងចំនួនឆ្នាំ ១២ បានចំនួនប៉ុន្មាន ? នៅសល់ប៉ុន្មាន ?

លី សុវីរ $\frac{៧៥}{១២}$ = ៦ នៅសេស ៣

យើងចាប់រាប់ពីលេខ ៧ បញ្ច្រាសអោយរបស់លេខសេសត្រឹមណា ត្រឹមនោះជាឆ្នាំកំណើត ។

ឧ.៧ មមី. ៦.ម្សាញ់.៥.រោង ។

ឧបាសក លី សុវីរ មានកំណើតពីឆ្នាំរោង ។

ឧ.២.ព្រះពុទ្ធសករាជ បាន ២៥៤៦ នៅឆ្នាំមមី ។ តើព្រះពុទ្ធសករាជ មានកំណើតពីឆ្នាំណា ?

$$ព.ស. \frac{២៥៤៦}{១២} = ២១២ \text{ នៅសេស } ២$$

យើងចាប់រាប់ ៧.មមី , ៦.ម្សាញ់

ដូចនេះ ព្រះពុទ្ធសករាជ មានកំណើតពីឆ្នាំម្សាញ់ ។

ឧ.៣.គ្រិស្តសករាជ បាន ២០០២ នៅឆ្នាំមមី ។ តើគ្រិស្តសករាជ មានកំណើតពីឆ្នាំណា ?

$$គ.ស. \frac{២០០២}{១២} = ១៦៦ \text{ នៅសេស } ១០$$

យើងចាប់រាប់ពីឆ្នាំ ៧.៦.៥.៤.៣.២.១.១២.១១. ១០ ។

ដូចនេះ គ្រិស្តសករាជ មានកំណើតពីឆ្នាំរកា ។

ឧ.៤.មហាសករាជ បាន ១៩២៤ នៅឆ្នាំមមី ។-តើមហា-សករាជមានកំណើតពីឆ្នាំណា ?

$$ម.ស. \frac{២០០២}{១២} = ១៦០ \text{ នៅសេស } ៤$$

យើងចាប់រាប់ពីឆ្នាំ ៧.៦.៥.៤ ។

ដូចនេះ មហាសករាជ មានកំនើតពីឆ្នាំថោះ ។

ឱ-៥.ចុល្លសករាជ បាន ១៣៦៤ នៅឆ្នាំមមី ។ តើចុល្លសករាជ មានកំនើតពីឆ្នាំណា ?

$$ច.ស. \frac{១៣៦៤}{១២} = ១១៣ \text{ នៅសេស } ៨$$

យើងចាប់រាប់ ពីឆ្នាំ៧.៦.៥.៤.៣.២.១.១២។

ដូចនេះ ចុល្លសករាជមានកំនើតពីឆ្នាំកុរ ។

# ឃ_ស្តីអំពី

# ពិធីរកឈ្មោះសករាជ

››››››❦‹‹‹‹‹

សករាជ ដែលខ្មែរមានយកមកប្រើនៅក្នុងសៀវភៅប្រវត្តិសាស្ត្រឃើញមាន ៥ ។ តែលោកប្រើសករាជ លោកមិនបានដាក់ថា ពុ.ស, ព.ស, ម.ស, ច.ស, គ.ស, ទេ លោកសរសេរថា លុះសករាជ ( ពង្សាវតារខ្មែរទំព័រ ៦៤ ) ១៦៦២ ឆ្នាំវក ថ្ងាយព្រះនាម អ្នករង្គ ធន់ ជាសម្តេចព្រះរៀមព្រះរាជឱង្ការព្រះស្រីធម្មរាជា,...តើយើង ដឹងថាសករាជ ១៦៦២នេះ ជាសករាជឈ្មោះអ្វី ?

មុននឹងលើកយក " ពិធីរកឈ្មោះសករាជ " មកនិយាយ ខ្ញុំសូមលើកយកកំណើតសករាជ និងឆ្នាំដើមរបស់សករាជមកបញ្ជាក់ :

**១.បុរាណសករាជ** មានកំណើតពីឆ្នាំកុរ មុនពុទ្ធសករាជ ៩១ឆ្នាំ ។ សករាជនេះមិនមានឯកសារណាបញ្ជាក់ថា មានប្រារព្ធនឹងបុគ្គលអស្ចារ្យណា រឺ ហេតុការណ៍ណាសោះ ហើយជាសករាជរបស់ខ្មែរសុទ្ធសាធ ( ទំព័រ ៨១បន្ទាត់ ៦ សុរិយាត្រឡើងស័ក លោកពៅ អ៊ុម ) ។ បច្ចុប្បន្នបុរាណសករាជមិនឃើញមានប្រើទេ ។

**២.ពុទ្ធសករាជ** ជាសករាជរបស់ព្រះពុទ្ធ ។ ពុទ្ធសករាជនេះ គេចាប់រាប់ពីថ្ងៃ ១រោច ខែពិសាខ ឆ្នាំម្សាញ់ ក្រោយថ្ងៃព្រះពុទ្ធបរិនិព្វានបាន ១ ថ្ងៃ ។

**៣.មហាសករាជ** មានកំណើតពីឆ្នាំថោះ (គ.ស ៧៩) ។

បញ្ជាក់

ឯកសារដែលបាននិយាយពីឆ្នាំដើម ដែលមហាសករាជបានកើតឡើង :

- សុរិយាត្រឡើងស័ក ទំព័រ១៦ បន្ទាត់ ១២ ថាឆ្នាំថោះ
- ពង្សាវតារខ្មែរ ចំលងចេញពីសាស្ត្រាស្លឹករឹត វត្តសិត្បូរ ទំព័រ១៥ បន្ទាត់១ ថា ព.ស ៦២១ ឆ្នាំឆ្លូវ
- ពង្សាវតាររបស់លោក ឧកគវាម ទំព័រ៤៣ ថា ព.ស ៦២១ ឆ្នាំឆ្លូវ
- វចនានុក្រមខ្មែរ ទំព័រ១២២៦ បន្ទាត់១០ ថា កាលពុទ្ធសករាជ ៦២១ ( មិនបានបញ្ជាក់ឈ្មោះឆ្នាំទេ ) ។ ឯកសារមានចំនួនច្រើនថា ព.ស ៦២១ ឆ្នាំឆ្លូវ ។

---

(១) ប្រវត្តិសាស្ត្រ ភាគ១ របស់លោក ចន្ទ្រាបុត្រ ត្រង់លេខយោង ទំព័រ ៥៧ ថា មហាសករាជ ចាប់ផ្តើមនៅថ្ងៃ ពុធ ១១ រោច ខែចេត្រ ឆ្នាំថោះ ព.ស ៦២៣ ត្រូវនឹងថ្ងៃ ១៧ មិនា គ.ស ៧៨ ។

តែមហាសករាជ ដែលយើងយកមកប្រើសព្វថ្ងៃនេះ មិនយកមហាសករាជឆ្នាំឆ្លូវទេ គឺយកតាមមហាសករាជឆ្នាំថោះវិញ (ខ្ញុំនឹងលើកបញ្ជាក់ពេលក្រោយ ) ។

**៤.ចុល្លសករាជ** មានកំនើតពីឆ្នាំកុរ ជាសករាជដែលបានយកគតិ នៃព្រះអាទិត្យនិងព្រះចន្ទរួមគ្នា (សុរិយាត្រឡើងស័ក )។

**៥.គ្រិស្តសករាជ** មានកំនើតពីឆ្នាំរកា ។ គេចាប់រាប់សករាជនេះ ពីថ្ងៃដែលព្រះសាស្តានេះកើតឡើងក្នុងលោក (ថ្ងៃទី ១ ខែ មករា ឆ្នាំរកា ) ។

## កំណត់សំគាល់

### អំពីសករាជ៤

- គ.ស.នៅក្នុងសៀវភៅដែលចំលងចេញពីសាស្ត្រាស្លឹករឹតគ្មានប្រើទេ
- គ.ស.នៅសម័យក្រោយ គេមានសរសេរនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ឯកសារនានា សំបុត្រស្នាមនានា... ។
- ម.ស.និង ច.ស.នៅសម័យបច្ចុប្បន្ន ស្ទើរតែគ្មានប្រើ។
- ព.ស. នៅមានប្រើច្រើនបន្តិច ។

**បញ្ជាក់ ៈ**

នៅក្នុងប្រទេសខ្មែរ ពីសម័យបុរាណ គេប្រើ ៈ

– បុរាណសករាជ និងពុទ្ធសករាជ តែនៅសម័យក្រោយមកគេឈប់ប្រើបុរាណសករាជ មិនដឹងជាមានមូលហេតុអ្វីទេ ។

– បន្ទាប់មក គេប្រើមហាសករាជ និងពុទ្ធសករាជ ជំនួសបុរាណសករាជ ។

– បន្ទាប់មកទៀត គេប្រើចុល្លសករាជ និងពុទ្ធសករាជ តែនៅពេលខ្លះគេប្រើសករាជ ៣ គឺ ពុទ្ធសករាជផង មហាសករាជផង ចុល្លសករាជផង លាយគ្នា នៅឯកសារខ្លះ ។

– នៅក្រោយឆ្នាំ ១៩៦៣ យូរ ឃើញមានឯកសារច្រើន មានប្រើគ្រិស្តសករាជ។ តែនៅពេលបច្ចុប្បន្ននេះ គេប្រើគ្រិស្តសករាជស្ទើរតែទាំងអស់។ តែបើអ្នកកាន់ព្រះពុទ្ធសាសនា មានប្រើពុទ្ធសករាជលាយនឹង គ្រិស្តសករាជ ។

យើងគួរពិចារណា អោយបានច្បាស់ថា តើយើងគួរ ស្រលាញ់ជាតិ គួរស្រលាញ់ព្រះពុទ្ធសាសនា រឺគួរស្រលាញ់ព្រះគ្រិស្ត ?

## I.ពិធីរកឈ្មោះសករាជ បែបទី១

### ត្រូវចងចាំអោយច្បាស់

### នៅឆ្នាំដើមសករាជ ៤

១.ពុទ្ធសករាជ ឆ្នាំម្សាញ់

២.មហាសករាជ ឆ្នាំថោះ

៣. ចុល្លសករាជ ឆ្នាំកុរ

៤. គ្រិស្តសករាជ ឆ្នាំរកា ។

### ត្រូវចេះអំពីវិធីបំប្រួញលេខ

**១.បែបទី ១**

បើមានអាយុចំនួន ១ឆ្នាំ ដល់ ១៩ ឆ្នាំ ត្រូវរាប់ធម្មតា

បើមានអាយុចំនួន ២០ ឆ្នាំអោយរាប់ ៨

បើមានអាយុចំនួន ៣០ ឆ្នាំអោយរាប់ ៦

បើមានអាយុចំនួន ៤០ ឆ្នាំ អោយរាប់ ៤

បើមានអាយុចំនួន ៥០ ឆ្នាំ អោយរាប់ ២

បើមានអាយុចំនួន ៦០ ឆ្នាំ អោយរាប់ ១២

បើមានអាយុចំនួន ៧០ ឆ្នាំ អោយភាប់ ១០

បើមានអាយុចំនួន ៨០ ឆ្នាំ អោយភាប់ ៨

បើមានអាយុចំនួន ៩០ ឆ្នាំ អោយភាប់ ៦

បើមានអាយុចំនួន ១០០ ឆ្នាំ អោយភាប់ ៤

បើមានអាយុចំនួន ១ ០០០ ឆ្នាំ អោយភាប់ ៤

បើមានអាយុចំនួន ១០ ០០០ ឆ្នាំ អោយភាប់ ៤។ ...

លេខ ៨.៦.៤.....ខ្ញុំអោយឈ្មោះថាលេខរបាប់តាង ។

២.វិបបទី២

បើលេខខ្ទង់រយ, ខ្ទង់ពាន់ នឹងខ្ទង់ម៉ឺន,...មានចំនួនលើស ពី១ ត្រូវយកលេខទាំងនោះទៅគុណនឹងចំនួន ៤ជានិច្ច

ឧទាហរណ៍

-បើមានចំនួន ៣០០ អោយយក ៣ x ៤ = ១២

-បើមានចំនួន ២០០ អោយយក ២ x ៤ = ៨

-បើមានចំនួន ២ ០០០ អោយយក ២ x ៤ = ៨

-បើមានចំនួន ៥ ០០០ អោយយក ៥ x ៤ = ២០

-បើមានចំនួន ២០០ ០០០ អោយយក ២ x ៤ = ៨

-បើមានចំនួន ៣០០ ០០០ អោយយក ៣ x ៤ = ១២

**ឧទាហរណ៍ ក**

ខ្ញុំសូមលើកយកឧទាហរណ៍ ចេញពីសៀវភៅពង្សាវតារខ្មែរដែលបានចំលងចេញពីសាស្ត្រាស្លឹករឹត វត្តសិត្បូរ ត្រង់ទំព័រ ៥៦ បន្ទាត់៥ថាលុះសករាជ ១៥៨០ ឆ្នាំច ព្រះជន្មព្រះវស្សា គំរប់ជាឆ្នាំ ៣៩ ...

តើសករាជនេះជាសករាជឈ្មោះអ្វី ?

១៥៨០< ( ១ x ៤ ) + ( ៥ x ៤ ) +៨០ =

៤ + ២០ + ៨ = ៣២

៣២ = ៣០ + ២ = ៦ + ២ = ៨

- បើរាប់ពី ព.ស.ម្សាញ់ ដល់លេខ ៨ = ឆ្នាំជូត
- បើរាប់ពី ម.ស. ថោះ ដល់លេខ ៨ = ឆ្នាំច
- បើរាប់ពី ច.ស. កុរ ដល់លេខ ៨ = ឆ្នាំមមី

ដូចនេះ សករាជនេះ ជាមហាសករាជ ។

**ឧទាហរណ៍ ខ**

មហាសករាជ នៅក្នុងឯកសារ មានចំនួនច្រើនថា មានកំណើតពីឆ្នាំ ព.ស. ៦២១ តែមានឯកសារមួយចំនួនតូចថា មាន

កំនើតពីឆ្នាំថោះ ។ តើឯកសារថា ពីឆ្នាំឆ្លូវ ព.ស.៦២១ត្រូវ រឺឯកសារថា ឆ្នាំថោះត្រូវវិញ ?

នៅក្នុងឆ្នាំមមីបច្ចុប្បន្ននេះ មហាសករាជបាន ១៩២៤ តើមហាសករាជ មានកំនើតពីឆ្នាំណា ?

១៩២៤< ( ១ x ៤ ) + ( ៩ x ៤ ) +២៤ =

៤ + ៣៦ + ៨ + ៤ = ៥២

៥២ = ៥០ + ២ = ២ + ២ = ៤

- បើរាប់ពីឆ្នាំឆ្លូវ ដល់លេខ៤ ត្រូវជារោង

- បើរាប់ពីឆ្នាំថោះ ដល់លេខ ៤ ត្រូវជាឆ្នាំមមី ។

ដូចនេះ មហាសករាជ មានកំនើតពីឆ្នាំថោះ ។

ខ្ញុំសូមលើកឧទាហរណ៍ ចេញពីសៀវភៅ ពង្សាវតារខ្មែរ ចេញពីសាស្ត្រាស្លឹករឹត ដោយលោក ឌឹក គាម បានបោះពុម្ពពី ព.ស.២៥១៨ គ.ស. ១៩៧៥ មកបញ្ជាក់ជាបន្តទៅទៀត ។

តែនៅក្នុងសៀវភៅ គ្មានប្រើបុរាណសករាជ និង គ្រិស្តសករាជទេ ឃើញមានប្រើតែពុទ្ធសករាជ, មហាសករាជនិងចុល្លសករាជ ។ ដូចនេះ ត្រូវចាំឈ្មោះដើមឆ្នាំ សករាជទាំង ៣ :

- ព.ស. ឆ្នាំម្សាញ់
- ម.ស. ឆ្នាំថោះ
- ច.ស. ឆ្នាំកុរ ។

ឱ.ឆ១. ទំព័រ ៥២បន្ទាត់៤ បានបញ្ជាក់ថាសករាជ ១៥១៧ ឆ្នាំមមែ ព្រះរាមជើងព្រៃ លើកដេញទ័ពសៀម រត់ទៅនៅក្រុងទេពវិញ ... ។

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៥១៧< ( ១ x ៤ ) + ( ៥ x ៤ ) +១៧ =

៤ + ២០ + ១៧ = ៤១

៤១ = ៤០ + ១ = ៤ + ១ = ៥

- បើរាប់ពី ព.ស. ម្សាញ់ ដល់លេខ ៥ = ឆ្នាំរកា
- បើរាប់ពី ម.ស. ថោះ ដល់លេខ ៥ = ឆ្នាំមមែ
- បើរាប់ពី ច.ស. កុរ ដល់លេខ ៥ = ឆ្នាំថោះ ។

ដូចនេះ សករាជនេះ ជាមហាសករាជ ។

ឱ.ឆី២.ទំព័រ ៥៣ បន្ទាត់ ១៥ បានបញ្ជាក់សករាជ ១៥២៤ ឆ្នាំខាល គំរប់ជាឆ្នាំ២ ព្រះជន្មវស្សា គំរប់ជា ៤៧... ។

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៥២៤<( ១ x ៤ ) + ( ៥ x ៤ ) +២៤ =

៤ + ២០ + ២៤ =

៤ + ២០ + ៨ + ៤ = ៣៦

៣៦ = ៣០ + ៦ = ៦ + ៦ = ១២

- បើរាប់ពី ព.ស.ម្សាញ់ ដល់លេខ ១២ = ឆ្នាំរោង
- បើរាប់ពី ម.ស. ថោះ ដល់លេខ ១២ = ឆ្នាំខាល
- បើរាប់ពី ច.ស. កុរ ដល់លេខ ១២ = ឆ្នាំច

ដូចនេះ សករាជនេះជាមហាសករាជ ។

ឱ.ឆី៣. ទំព័រ ៥៥ បន្ទាត់ ៧ បានបញ្ជាក់ថា លុះ សករាជ ១៥៦០ ឆ្នាំខាល គំរប់ជា ៤ឆ្នាំ ទើបភ្ញៀវរបស់ (ភ្ញៀវរាប៉ស ) ព្រះអង្គចាប់បានហើយ... ។

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៥៦០<( ១ x ៤ ) + ( ៥ x ៤ ) +៦០ =

៤ + ២០ + ១២ = ៣៦

៣៦ = ៣០ + ៦ = ៦ + ៦ = ១២

- បើរាប់ពី ព.ស.ម្សាញ់ ដល់លេខ ១២ = ឆ្នាំរោង
- បើរាប់ពី ម.ស. ថោះ ដល់លេខ ១២ = ឆ្នាំខាល
- បើរាប់ពី ច.ស. កុរ ដល់លេខ ១២ = ឆ្នាំច

ដូចនេះ សករាជនេះ ជាមហាសករាជ ។

ខ.ឆ៤. ទំព័រ ៥៦ បន្ទាត់១៦ បានបញ្ជាក់ថា លុះ សករាជ ១៤២៤ ឆ្នាំជូត គំរប់ជា ៣៧ ព្រះជន្មវស្សា ៥៨សុគត...

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៤២៤<( ១ x ៤ ) + ( ៤ x ៤ ) +២៤ =

៤ + ១៦ + ៨ + ៤ = ៣២

៣២ = ៣០ + ២ = ៦ + ២ = ៨

- បើរាប់ពី ព.ស. ម្សាញ់ ដល់លេខ ៨ = ឆ្នាំជូត
- បើរាប់ពី ម.ស. ថោះ ដល់លេខ ៨ = ឆ្នាំច

- បើរាប់ពី ច.ស. កុរ  ដល់លេខ ៨ = ឆ្នាំមមី

ដូចនេះ សករាជនេះ ជាពុទ្ធសករាជ ។

ឱ.ឥ៥. ទំព័រ ៤៨ បន្ទាត់ ១៤ បានបញ្ជាក់ថា លុះសករាជ ១៤៩២ ឆ្នាំមមី ស្ដេចគ្រងនៅបន្ទាយលង្វែក គំរប់ជា ឆ្នាំ៥ ....

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៤៩២ < ( ១ x ៤ ) + ( ៤ x ៤ ) + ៩២ =

៤ + ១៦ + ៦ + ២ = ២៨

២៨ = ២០ + ៨ = ៨ + ៨ = ១៦ (១)

- បើរាប់ពី ព.ស. ម្សាញ់ ដល់លេខ ១៦ = ឆ្នាំវក
- បើរាប់ពី ម.ស. ថោះ ដល់លេខ ១៦ = ឆ្នាំមមី
- បើរាប់ពី ច.ស. កុរ  ដល់លេខ ១៦ = ឆ្នាំខាល

ដូចនេះ សករាជនេះ ជាមហាសករាជ ។

---

(១) យក ១៦ សង ១២ នៅសល់ ៤ យកចំនួន ៤ រាប់ក៏ត្រូវដូចជា ១៦ដែរ។

ខ.ឆ៦. ទំព័រ ៤៩ បន្ទាត់ ៦ បានបញ្ជាក់ថា លុះសករាជ ១២៧៩ ឆ្នាំរកា គំរប់ជា ៣ ព្រះចៅបាអាត សុគត ...

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១២៧៩<( ១ x ៤ ) + ( ២ x ៤ ) +៧៩ =

៤ + ៨ +១០ + ៩ = ៣១

៣១ = ៣០ + ១ = ៦ + ១ = ៧

- បើរាប់ពី ព.ស. ម្សាញ់ ដល់លេខ ៧ = ឆ្នាំកុរ
- បើរាប់ពី ម.ស. ថោះ ដល់លេខ ៧ = ឆ្នាំរកា
- បើរាប់ពី ច.ស. កុរ ដល់លេខ ៧ = ឆ្នាំម្សាញ់

ដូចនេះ សករាជនេះ ជាមហាសករាជ ។

ខ.ឆ៧. ទំព័រ ៤៦ បន្ទាត់ ៥ បានបញ្ជាក់ថា លុះសករាជ ១៤៥២ ឆ្នាំរោង គំរប់ជាឆ្នាំ ៥ មានព្រះរាជបុត្រ ១ព្រះអង្គ មាននាម ឈ្មោះព្រះបរមរាជា... ។

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៤៥២<( ១ x ៤ ) + ( ៤ x ៤ ) + ៥២ =

៤ + ១៦ + ២ + ២ = ២៤

២៤ = ២០ + ៤ = ៨ + ៤ = ១២

- បើរាប់ពី ព.ស. ម្សាញ់ ដល់លេខ ១២ = ឆ្នាំរោង
- បើរាប់ពី ម.ស. ថោះ ដល់លេខ ១២ = ឆ្នាំខាល
- បើរាប់ពី ច.ស. កុរ ដល់លេខ ១២ = ឆ្នាំច

ដូចនេះ សករាជនេះ ជាពុទ្ធសករាជ ។

ឧ.ឆ៨. ទំព័រ ១៤៩ បន្ទាត់ ៨ បានបញ្ជាក់ថា លុះដល់ ១៧៨០ ឆ្នាំមមី សំរឹទ្ធិស័ក សម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ស្តេចនាំព្រះរាជបុត្រី ព្រះបរមមេយូរព្រះស្នំ ព្រះមេម្នាង សៅឡឹក អកយាយ ចាស់ទុំចេញពីបន្ទាយ....។

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៧៨០ <( ១ x ៤ ) + ( ៧ x ៤ ) + ៨០ =

៤ + ២៨ + ៨ = ៤០ = ៤

- បើរាប់ពី ព.ស. ម្សាញ់ ដល់លេខ ៤ = ឆ្នាំវក
- បើរាប់ពី ម.ស. ថោះ ដល់លេខ ៤ = ឆ្នាំមមី

- បើរាប់ពី ច.ស. កុរ ដល់លេខ ៤ = ឆ្នាំខាល

ដូចនេះ សករាជនេះ ជាមហាសករាជ ។

ឱ.ឆ៩.ទំព័រ ១៤៧ បន្ទាត់ ១០ បានបញ្ជាក់ថា លុះសករាជ ១៧៧៨ ឆ្នាំរោង នៅក្នុងខ្នើត ខែអាសាធ សម្តេច ព្រះចមក្សៅ ព្រះចៅវាំងល្វង ស្តេចបំបួស ព្រះអង្គរាជវតី ទ្រង់ព្រះផ្នួសជាភិក្ខុ... ។

តើសករាជនេះ ជាសករាជឈ្មោះអ្វី ?

១៧៧៨< ( ១ x ៤ ) + ( ៧ x ៤ ) +៧៨ =

៤ + ២៨ + ១០ + ៨ = ៥០ = ២

- បើរាប់ពី ព.ស. ម្សាញ់ ដល់លេខ ២ = ឆ្នាំមមី

- បើរាប់ពី ម.ស. ថោះ ដល់លេខ ២ = ឆ្នាំរោង

- បើរាប់ពី ច.ស. កុរ ដល់លេខ ២ = ឆ្នាំជូត

ដូចនេះ សករាជនេះ ជាមហាសករាជ ។

# បញ្ជាក់នៃការប្រើស័ក

សករាជទាំងអស់ ដែលមានប្រើស័ក គេអោយឈ្មោះតាមលេខដែលមាននៅខាងចុង ។

ឱ.បើគេឃើញលេខខាងចុងចំនួនសូន្យ ( ០ ) គេអោយឈ្មោះថា សំរឹទ្ធិស័ក, បើគេឃើញចំនួន ១ គេអោយឈ្មោះឯកស័ក,បើឃើញចំនួន ២ គេអោយឈ្មោះថា ទោស័ក , បើគេឃើញចំនួន ៣ គេអោយឈ្មោះថា ត្រីស័ក, បើគេឃើញចំនួន ៤ គេអោយឈ្មោះថា ចត្វាស័ក , បើគេឃើញចំនួន ៥ គេអោយឈ្មោះថា បញ្ចស័ក, បើគេឃើញចំនួន ៦ គេអោយឈ្មោះថា ឆស័ក,បើគេឃើញចំនួន ៧ គេអោយឈ្មោះថា សប្តស័ក ,បើគេឃើញចំនួន ៨ គេអោយឈ្មោះថា អដ្ឋស័ក, បើគេឃើញចំនួន ៩ គេអោយឈ្មោះថា នពស័ក ។

ខ្ញុំសូមលើកឧទាហរណ៍ជាក់ស្តែង នៅក្នុងសៀវភៅពង្សាវតារខ្មែរ ដែលបានចំលងចេញ ពីសាស្ត្រាប្រវត្តិសាស្ត្រ វត្តសិត្បូរ ដោយលោក ឌឹក គាម :

## ១.ពុទ្ធសករាជ

ទំព័រ ៤៦ បន្ទាត់ ១៦ បានបញ្ជាក់ថា សករាជ ១៤២៤ ឆ្នាំជូត ចត្វាស័ក គំរប់ជាឆ្នាំ ៣៧ ព្រះជន្មវស្សា ៥៨ សុគត...។

ចត្វាស័កនេះ ជាស័ករបស់ពុទ្ធសករាជ ។

## ២.មហាសករាជ

ទំព័រ ១៤៨ បន្ទាត់ ៨ បានបញ្ជាក់ថា សករាជ១៧៧៩ ឆ្នាំម្សាញ់ នពស័ក សម្តេចព្រះរាជឱង្ការព្រះហរិរក្សមាឥស្សរាធិបតី ត្រាស់បង្គាប់អោយធ្វើសព្វរក្សរ... ។

នពស័កនេះ ជាស័ករបស់មហាសករាជ ។

## ៣.ចុល្លសករាជ

ទំព័រ ៣៩៤ បន្ទាត់ ១៨ បានបញ្ជាក់ថា ចុល្លសករាជ ១២២២ ឆ្នាំវក ទោស័ក សម្តេចព្រះនរោត្តមព្រហ្មបរិរក្សាមហាឧបរាជ... ។

ទោស័កនេះ ជាស័ករបស់ចុល្លសករាជ ។

**សូមជួយសង្កេត**

- សករាជ ១៧៦២ គេឃើញលេខ២នៅចុង គេអោយឈ្មោះទោស័ក

- សករាជ ១៧៧៩ គេឃើញលេខ ៩ នៅចុងគេអោយឈ្មោះ នពស័ក

- សករាជ ១៧៥៧ គេឃើញលេខ ៧ នៅចុង គេអោយឈ្មោះ សប្តស័ក

ដូចនេះ ឈ្មោះស័ក គេកំនត់អោយឈ្មោះតាមចំនួនលេខដែលនៅខាងចុង :

- បើលេខ ០ គេអោយឈ្មោះថា សំរឹទ្ធិស័ក ។
- បើលេខ ១ គេអោយឈ្មោះថា ឯកស័ក
- បើលេខ ២ គេអោយឈ្មោះថា ទោស័ក
- បើលេខ ៣ គេអោយឈ្មោះថា ត្រីស័ក
- បើលេខ ៤ គេអោយឈ្មោះថា ចត្វាស័ក
- បើលេខ ៥ គេអោយឈ្មោះថា បញ្ចស័ក
- បើលេខ ៦ គេអោយឈ្មោះថា ឆស័ក
- បើលេខ ៧ គេអោយឈ្មោះថា សប្តស័ក
- បើលេខ ៨ គេអោយឈ្មោះថា អដ្ឋស័ក

- បើលេខ ៩ គេអោយឈ្មោះថា នពស័ក ។

បានន័យថា នៅគ្រប់សករាជទាំង ៥ គឺបុរាណសករាជ, ពុទ្ធសករាជ, មហាសករាជ, ចុល្លសករាជ និងគ្រិស្តសករាជ សករាជទាំងនេះ សុទ្ធតែមានលេខនៅខ្ទង់ចុងដូចគ្នា តាំងពីលេខ ០ ដល់លេខ ៩ ។

ឯឈ្មោះស័ក កាលបើគេឃើញលេខប៉ុន្មាន គេអោយឈ្មោះ ស័កនោះ តែម្តង ។ ឧទាហរណ៍ ឆ្នាំមមី :

- ព.ស. ២៥៤៦ ឆស័ក
- ម.ស. ១៩២៤ ចត្វាស័ក
- ច.ស. ១៣៦៤ ចត្វាស័ក
- គ.ស. ២០០២ ទោស័ក ។

ចុះហេតុអ្វីបានជាបច្ចុប្បន្ននេះ នៅឆ្នាំមមី មានប្រើស័កតែ ១ គឺចត្វាស័ក ?

ពីព្រោះ :

- បើដាក់ឈ្មោះអោយស័កទាំងអស់ វាច្រើនពេក ។

- ទើបគេដាក់តែ មហាសករាជ ១ ដែលជា ស័ក មាន ប្រើមុនគេ ជាពិនវស្សយូរអង្វែងណាស់ផង ជាស័ក ដែលជា ប្រវត្តិ បង្កើតស័កផង ។

**បញ្ជាក់ :**

មហាសករាជ, ចុល្លសករាជ,គ្រិស្តសករាជ ,លោកបានចុះ ទៅក្នុងឯកសារនានា មានការឯកភាព ពីដើមដល់ចប់ ។ ផ្ទុយ ទៅវិញ ពុទ្ធសករាជ មិនមានការឯកភាព ពីដើមដល់ចប់សោះ ព្រោះហេតុអ្វី ?

ព្រោះមានហេតុ ២ យ៉ាង :

១- នៅមុនសម័យបារាំងចូលស្រុកខ្មែរ ពុទ្ធសករាជ គ្រាន់ តែចូលបាន១ ថ្ងៃ គេរាប់ថា ឆ្នាំម្សាញ់ឯកស័ក ។ ខ្ញុំបានអោយ ឈ្មោះការរាប់បែបនេះថា ពុទ្ធសករាជបច្ចុប្បន្ន ។

តែនៅសម័យបារាំងត្រួតត្រា ពុទ្ធសករាជ លុះត្រាតែគ្រប់ ពេញ ១ ឆ្នាំ គឺរាប់ថ្ងៃ ១រោច ខែពិសាខ ឆ្នាំម្សាញ់ រហូតដល់ថ្ងៃ ១រោច ខែ ពិសាខ ឆ្នាំ មមី ទើបគេរាប់ថា ១បាន,...ការរាប់ សករាជបែបនេះ ខ្ញុំអោយឈ្មោះថា ពុទ្ធសករាជអតីត ។

នៅពេលបារាំងបានចេញពីស្រុកវិញ ការរាប់ពុទ្ធសករាជ មានលក្ខណៈ ដូចដើមវិញ គឺគេរាប់ដូចដើមវិញ ពីថ្ងៃអាទិត្យ ១ រោច ខែពិសាខ ឆ្នាំវក ព.ស.២៥១២ ត្រូវនឹងថ្ងៃទី ១២ ខែ ឧសភា គ.ស.១៩៦៨ រហូតដល់សព្វថ្ងៃនេះ ។

សូមពិនិត្យមើល ទស្សនាវដ្ដី ពន្លឺពុទ្ធចក្រ លេខ ២៨,២៩ ៣០ និងពុទ្ធសករាជ " ការប្រើពុទ្ធសករាជនៅស្រុកខ្មែរ មានការ មិនឯកភាពពីដើមដល់ចប់ " បោះពុម្ពពី ព.ស.២៥៤៣ គ.ស. ១៩៩៩ ។

២. នៅចន្លោះឆ្នាំ គ្រីស្តសករាជ និង ពុទ្ធសករាជ ប្រើនចុះ ឆ្នាំពុទ្ធសករាជខុស ពីព្រោះឆ្នាំគ្រីស្តសករាជដាច់មុនឆ្នាំពុទ្ធសករាជ តិចណាស់ក៏៤ខែដែរ ។ ម្លោះហើយ ចំនួន៤ខែ ដែលនៅចន្លោះនេះ ជាហេតុធ្វើអោយអ្នកចុះលេខនៅក្នុងឯកសារនានា មានការភាន់ ច្រលំច្រើន ។

ឧ.ការចុះលេខបោះពុម្ពនៅក្នុងសៀវភៅ ពង្សាវតារខ្មែរ ថា ព.ស.២៥១៨ គ.ស.១៩៧៥ ។ ការចុះបែបនេះត្រឹមត្រូវ ណាស់ ពីព្រោះពុទ្ធសករាជ មិនទាន់ដាច់ឆ្នាំ គឺស្ថិតនៅក្នុងឆ្នាំ ខាល ។ ឯឆ្នាំ គ.ស.បានដាច់ឆ្នាំខាលនោះហើយ ។

## II.ពិធីរកឈ្មោះសករាជបែបទី ២

ឯពិធីរកឈ្មោះសករាជបែបទី២នេះ មានភាពងាយស្រួលជាងពិធីរកឈ្មោះសករាជបែបទី ១ ពីព្រោះ :

១. គ្រាន់តែដឹងលេខសករាជ និងឈ្មោះឆ្នាំ

២. យកលេខសករាជ ទៅចែកនិងចំនួន ១២.( លេខឆ្នាំ)

៣. បើលេខណា ចែកដាច់នឹងចំនួន ១២ ចាត់ទុកជាលេខសេសសូន្យ ( ០ ) មានតំលៃស្មើនឹងសេសចំនួន ១២ ។

៤.កាលបើចែកទៅហើយ ឃើញលេខសេសពី ១ដល់១១ ក៏ចាត់ជាលេខសេសដែរ ។

៥. បើយើងចង់ដឹងថា សករាជ ជាសករាជឈ្មោះអ្វី ? យើងត្រូវយកឆ្នាំដើមសករាជទាំងអស់ មករាប់បន្តដល់អស់លេខ ( រាប់ដូចមេរៀនទី ១ ) ។

ខ្ញុំសូមលើកឧទាហរណ៍ ដែលមានទៅក្នុងមេរៀនបែបទី ១ ពីលេខ១ ដល់លេខ ៩ មកបញ្ជាក់អោយបានឆាប់យល់ :

ឧ.ទី១. $\frac{១៥១៧}{១២}$ = ១២៦ សេសចំនួន ៥

ឧ.ទី២. $\frac{១៥២៤}{១២}$ = ១២៧ សេសសូន្យស្មើនឹង ១២

ឧ.ទី៣. $\frac{១៥៦០}{១២}$ = ១៣០ សេសសូន្យស្មើនឹង ១២

ឧ.ទី៤ $\frac{១៤២៤}{១២}$ = ១១៨ សេសបំនួន ៨

ឧ.ទី៥ $\frac{១៤៩២}{១២}$ = ១២៤ សេសបំនួន ៤

ឧ.ទី៦. $\frac{១២៧៩}{១២}$ = ១០៦ សេសបំនួន ៧

ឧ.ទី៧. $\frac{១៤៥២}{១២}$ = ១២១ សេសសូន្យស្មើនឹង ១២

ឧ.ទី៨. $\frac{១៧៨០}{១២}$ = ១៥៨ សេសបំនួន ៤

ឧ.ទី៩ $\frac{១៧៧៨}{១២}$ = ១៤៨ សេសបំនួន ២

## សូមបញ្ជាក់ ឧ.ទី៥.

ពិធីរកឈ្មោះសករាជបែបទី ១

១៤៩២<( ១ x ៤ ) + ( ៤ x ៤ ) + ៩២ =

៤ + ១៦ + ៦ + ២ = ២៨

២៨ = ២០ + ៨ = ៨ + ៨ = ១៦

- ពិធីរកឈ្មោះសករាជបែបទី ២

$\frac{១៤៩២}{១២}$ = ១២៤ សេសចំនួន ៤ ។

យើងសង្កេតឃើញថា ពិធីរកឈ្មោះសករាជបែបទី ១ មានចំនួនលេខ ១៦ ។ តែពិធីរកឈ្មោះសករាជបែបទី២ វិញ ឃើញលេខសេសចំនួន៤ ។ តែលេខសេសចំនួន១៦ (លេខរបាប់គាង១៦ ) និងលេខសេសចំនួន ៤នេះ មានពិធីរកឈ្មោះសករាជឃើញដូចគ្នា ពីព្រោះលេខសេសចំនួនណា ដែលមានចំនួនលើសពីចំនួន ១២ ត្រូវយកចំនួន ១២សង ឧ.១៦-១២=៤ ឃើញថា លេខសេសចំនួន ៤ ដូចគ្នា ។ លេខសេស ដែលមានលក្ខណៈ

បែបនេះ ទុកសំរាប់យកទៅរាប់រកឈ្មោះ សករាជ ដែលយើងចង់ដឹង ។

**សេចក្តីសង្ខេប**

វប្បធម៌-អរិយធម៌ ដែលបានស្តីអំពី រាប់ថ្ងៃ ខែ ឆ្នាំក្តី រាប់ ទសវត្ស សតវត្ស សហស្សវត្សក្តី រាប់រកអាយុ និងឆ្នាំកំនើតក្តី ពិធីរកឈ្មោះសករាជក្តី មានរបៀបរកច្រើនបែបយ៉ាង តាមគំនិតប្រាជ្ញារបស់លោកអ្នកប្រាជ្ញ បានចងក្រងទុកសំរាប់បច្ឆាជន ។

សូមបច្ឆាជន មេត្តាជួយរៀបចំចងក្រងជាក្បួនសំរាប់បច្ឆាជនជាន់ក្រោយ ស្តីអំពី រាប់ថ្ងៃ ខែ ឆ្នាំ, រាប់ ទសវត្ស សតវត្ស សហស្សវត្ស, រាប់រកអាយុ និងឆ្នាំកំនើត,ពិធីរកឈ្មោះសករាជ ធ្វើបន្តអោយបានច្បាស់ជាងនេះ ។

សូមលើកសៀវភៅនេះទាំងមូល ជូនអ្នកប្រាជ្ញទាំងអស់ ជួយរិះគន់ស្ថាបនា ដោយហៅខ្ញុំសួរក្តី ដោយសំបុត្ររិះគន់ស្ថាបនាក្តី ។ ខ្ញុំរង់ចាំទទួលការរិះគន់ ដោយសេចក្តីរីករាយជាទី

បំផុត ដើម្បីធ្វីសៀវភៅនេះ អោយមានភាពល្អប្រសើរ បានរស់នៅក្នុងសង្គមខ្មែរ ។

សូមអរគុណជានិច្ច

**លី សុទីរ**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

រក្សាសិទ្ធិ

**ទូរស័ព្ទលេខ : 016 862923**

## បញ្ចសីលា សីល៥

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ,**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ,**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាក កិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

**កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ,**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាក កិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ,**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាក ពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ ជាទីតាំងនៃ សេចក្ដីប្រមាថ គឺសេពនូវគ្រឿងស្រវឹង គឺសុរា និងមេរ័យ ។

បោះពុម្ពនៅរោងពុម្ព ម៉េងហាវ

Printed by Meng Hao Printing House